**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| ឯកសារបកប្រែ |
| --- |
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 19-Nov-2015, 08:00 |
| CMS/CFO: Sann Rada |

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/០៧ កញ្ញា ២០០៩/អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: ក្រុមការពារក្ដីរបស់អ្នកស្រី អ៊ឹម ចែម

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៥

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ: **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ការពិនិត្យចំពោះការចាត់ថ្នាក់ឯកសារបណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សេចក្ដីសង្ខេបរបស់អ្នកស្រី អ៊ឹម ចែម ស្ដីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា “មេដឹកនាំជាន់ខ្ពស់” ឬ បុគ្គលម្នាក់ស្ថិតក្នុងចំណោម “អ្នកទទួលខុសត្រូវខ្ពស់បំផុត”**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី**

លោក ប៊ិត ស៊ាងលឹម

លោក John R.W.D. JONES QC

**<u>ចម្លងជូន៖</u>**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ក្រុមមេធាវីការពារក្ដី អោ អាន**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤**

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតបានស្នើភាគីក្នុងសំណុំរឿង 004 ឲ្យដាក់សេចក្តីសង្កេតនានាដែលភាគីមាន ថាតើសហចៅក្រមស៊ើបអង្កេត នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន គួរចាត់ទុកអ្នកស្រី អ៊ឹម ចែម ជា "មេដឹកនាំជាន់ខ្ពស់" ឬជនម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[1] លើឧក្រិដ្ឋកម្មស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងនៅ អ.វ.ត.ក ដែរឬទេ[2]។ អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីការពារក្តីរបស់អ្នកស្រី ("ក្រុមការពារក្តី") សូមដាក់នូវសេចក្តីសង្កេតទាំងនេះ អនុលោមតាមសំណើរបស់សហចៅក្រមស៊ើបអង្កេត។ ដោយសារតែការកំណត់ថាតើអ្នកស្រី អ៊ឹម ចែម ជាបុគ្គលម្នាក់ក្នុងប្រភេទណាមួយក៏ដោយ ក្នុងចំណោមប្រភេទទាំងពីរ នឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់លទ្ធផលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងរបស់អ្នកស្រី ទើបក្រុមការពារក្តីសុំស្នើឲ្យមានឱកាសដើម្បីលើកទឡ្ហីករណ៍ផ្ទាល់មាត់ស្តីពីបញ្ហានេះ។

២. នៅពេលអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតត្រូវតែត្រិះរិះពិចារណាលើក្របខណ្ឌនៃកិច្ចព្រមព្រៀង ដោយស៊ើបអង្កេតតែលើបុគ្គលពីរប្រភេទប៉ុណ្ណោះ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[3]។ ហេតុដូច្នេះ មុខងាររបស់តុលាការត្រូវបាន

---

[1] សំណើសុំដាក់សារណាថាតើ [អ្នកស្រី] អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" និង/ឬជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ធ្វើនៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥, ឯកសារ D251 ("សំណើសុំដាក់សារណារបស់សហចៅក្រមស៊ើបអង្កេត") ត្រង់កថាខណ្ឌ ៨ ។

[2] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង") ផ្នែកបុព្វកថា ត្រង់មាត្រា ១ ។

[3] មាត្រា ៥(៣) នៃកិច្ចព្រមព្រៀង ។ *សូមមើលផងដែរ សំណុំរឿងរបស់លោក មាស មុត,* សំណុំរឿងលេខ ០០៣/០៧ កញ្ញា ២០០៩/អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើយុត្តាធិការបុគ្គល និងគោលការណ៍ស៊ើបសួរពាក់ព័ន្ធនឹងជនសង្ស័យ [កោសលប់] ធ្វើនៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២, ឯកសារ D49 ត្រង់កថាខណ្ឌ ១៣។

កំហិតឲ្យយក "មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត និង "បុគ្គលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត" ទៅកាត់ទោស[4]។ តាម*ការវាយតម្លៃជាបឋម* លើឯកសារមួយចំនួន ប្រមូលបានពីកិច្ចស៊ើបសួរដែលបានចំណាយពេលអស់ជាងប្រាំមួយឆ្នាំកន្លងផុតទៅ[5] បង្ហាញឲ្យឃើញថា ការថ្លឹងថ្លែងពីភាពដែលអាចទៅរួច អ្នកស្រី អ៊ឹម ចែម គឺមិនស្ថិតក្នុងប្រភេទបុគ្គលទាំងពីរនេះឡើយ។ ក្នុងឋានៈជាលេខាស្រុកតាមការចោទប្រកាន់ អ្នកស្រីគឺជាកម្មាភិបាលថ្នាក់ទាបមួយរូប ហើយគ្មានអ្វីត្រូវសង្ស័យឡើយ ដែលថាអ្នកស្រីពិតជាមិនស្ថិតនៅក្នុងប្រភេទ "មេដឹកនាំជាន់ខ្ពស់" នោះទេ។ អ្នកស្រី អ៊ឹម ចែម ក៏មិនស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរ ដោយហេតុថា មានតែភស្តុតាងបន្តិចបន្តួច ឬ ក៏គ្មានគ្មានភស្តុតាងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលអ្នកស្រីត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ដោយទុកដោយឡែកនូវភាពធ្ងន់ធ្ងររបស់ឧក្រិដ្ឋកម្មទាំងនោះ និងមានភស្តុតាងតិចណាស់ដែលថា អ្នកស្រី អ៊ឹម ចែម ទាក់ទងនឹងឧក្រិដ្ឋមួយចំនួនដែលអ្នកស្រីរងការចោទប្រកាន់ ។

៣. ផ្អែកលើសេចក្តីសង្កេតដែលបានបរិយាយនៅក្នុងទំព័រខាងក្រោម ដូចដែលក្រុមការពារក្តីស្នើសុំដោយក្តីគោរពទៅសហចៅក្រមស៊ើបអង្កេត ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ៖ (ក) សម្រេចថា អ្នកស្រី អ៊ឹម ចែម មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការលើរឿងក្តីរបស់តុលាការ និង (ខ) បដិសេធចោលនូវការចោទប្រកាន់ប្រឆាំងនឹង អ្នកស្រី អ៊ឹម ចែម។

៤. ក្រុមការពារក្តីសុំដាក់សេចក្តីសង្កេតទាំងនេះជាភាសាអង់គ្លេសមុន ហើយយើងខ្ញុំនឹងដាក់ជាភាសា

---

[4] *សំណុំរឿងរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច*, សំណុំរឿងលេខ ០០១/១៨ កក្កដា២០០៧/អ.វ.ត.ក/អ.ជ.ត.ក, សាលដីកា ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ F28 ("សាលដីកា*ឌុច*") ត្រង់កថាខណ្ឌ ៥៧។ *សូមមើលផងដែរ* ផ្នែកបុព្វកថា មាត្រា ១ កិច្ចព្រមព្រៀង ។

[5] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (ដែលត្រូវដាក់ជូនជាផ្លូវការនៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩) ឯកសារ D1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី")។

ខ្មែរឱ្យបានឆាប់បំផុត ដូចដែលសហចៅក្រមស៊ើបអង្កេតបានអនុញ្ញាត[6]។

## II. ការពិចារណាបឋម

### ក. នីតិវិធីក្នុងការសម្រេចថាតើជនត្រូវចោទជា "មេដឹកនាំជាន់ខ្ពស់" ឬ ជាបុគ្គលដែលស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"

៥. យោងតាមកិច្ចព្រមព្រៀង សហចៅក្រមស៊ើបអង្កេតមានភារកិច្ចដើម្បីធានាបានថា ជនត្រូវចោទស្ថិតក្នុងប្រភេទនៃបុគ្គលដែលពួកគាត់អាចធ្វើការស៊ើបអង្កេតបាន។ យោងតាមមាត្រា ៥(៣) នៃកិច្ចព្រមព្រៀង ចែងដូច្នេះថា "វិសាលភាពនៃការស៊ើបអង្កេត គឺកំណត់ត្រឹមតែលើមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការរឿងក្តីរបស់តុលាការនេះ[7]។ វិសាលភាពដែលបានកំណត់ក្នុងបញ្ញត្តនេះស្របជាមួយគោលបំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ទាំងមូល ដែលគោលបំណងនោះ គឺដើម្បីដើម្បីជំនុំជម្រះតែ "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដូចបានលើកឡើងខាងលើ[8]។

៦. សហចៅក្រមស៊ើបអង្កេតមិនអាចបន្តកិច្ចស៊ើបសួរលើអ្នកស្រី អ៊ឹម ចែម បានឡើយ ប្រសិនបើពួកគាត់ជឿជាក់ថា អ្នកស្រី អ៊ឹម ចែម មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ឬ ជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" តាមរយៈ*ការវាយតម្លៃបឋម* លើភស្តុតាង[9]។ ពួកគាត់ត្រូវ

---

[6] ដីកាសម្រេចលើសំណើសុំបន្ថែមពេលវេលា និងសុំដាក់ [ឯកសារជូន] មួយភាសា ធ្វើនៅថ្ងៃទី១ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារ D251/3។

[7] មាត្រា៥(៣) នៃកិច្ចព្រមព្រៀង។

[8] ផ្នែកបុព្វកថា មាត្រា ១ នៃកិច្ចព្រមព្រៀង ។

[9] *សូមមើលសំណុំរឿងរបស់លោក មាស មុត* សំណុំរឿងលេខ ០០៣/០៧ កញ្ញា ២០០៩/អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើយុត្តាធិការបុគ្គល និងគោលការណ៍ស៊ើបសួរទាក់ទងជនសង្ស័យ [កោសលប់] ធ្វើនៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២, ឯកសារ D49 ត្រង់កថាខណ្ឌ ៣ ។

តែអនុវត្តឆន្ទានុសិទ្ធិស៊ើបសួររបស់ខ្លួន "ដោយសុទ្ធចិត្តផ្អែកតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ"[10] ក្នុងក្របខណ្ឌដូចមានចែងក្នុងមាត្រា ៥(៣) នៃកិច្ចព្រមព្រៀង។ ការអនុវត្តដ៏ត្រឹមត្រូវនៃឆន្ទានុសិទ្ធិនេះ តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតច្រានចោលមិនធ្វើកិច្ចស៊ើបសួរ និងធ្វើការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម ប្រសិនបើអ្នកស្រីពុំស្ថិតក្នុងប្រភេទបុគ្គលទាំងពីរនេះ ព្រោះវាមិនស្ថិតក្នុងគោលបំណងដើម្បីអាចធ្វើការចោទប្រកាន់ទៅបានពីសំណាក់ភាគីនៃកិច្ចព្រមព្រៀង។

៧. ប្រសិនបើអ្នកស្រី អ៊ឹម ចែម មិនស្ថិតក្នុងប្រភេទបុគ្គលណាមួយនោះទេ កិច្ចដំណើរការនីតិវិធីត្រូវតែបញ្ចប់ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ការអូសបន្លាយពេលវេលា គឺជាការរំលោភលើសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីមួយ ដែលគ្មានការអូសបន្លាយពេលវេលាមិនសមហេតុផល[11]។ ហេតុដូចនេះ ក្រុមការពារក្ដីមិនឯកភាពឡើយ ចំពោះការសម្រេចរបស់ចៅក្រម Mark B. HARMON ដែលថាបញ្ហានេះ គួរត្រូវបានពិចារណានៅចុងបញ្ចប់នៃកិច្ចស៊ើបសួរ[12]។ សិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីដ៏ឆាប់រហ័សមួយ មានន័យថា ការសម្រេចថាតើអ្នកស្រីជា "មេដឹកនាំជាន់ខ្ពស់" ឬ ជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ត្រូវតែធ្វើជាបន្ត ដោយពិចារណាលើភស្តុតាងទាំងអស់ដែលប្រមូលបាននៅគ្រប់ដំណាក់កាលនៃកិច្ចស៊ើបសួរ។ ក្នុងករណីនេះ ការអូសបន្លាយពេលវេលាមិនសមហេតុផលណាមួយ នឹងមានផលប៉ះពាល់កាន់តែខ្លាំងដល់សិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ព្រោះថា កិច្ចស៊ើបសួរបានចំណាយពេលចំនួនជាងប្រាំមួយឆ្នាំរួចទៅហើយ។

---

[10] សាលដីកា*ឌុច* ត្រង់កថាខណ្ឌ ៨០។

[11] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦) 999 UNTS 171 ("ICCPR") ត្រង់មាត្រា ១៤(៣)(គ)។ *សូមមើល* មាត្រា ១២(២) នៃកិច្ចព្រមព្រៀង និង មាត្រា១៣(១) ដែលចែងថា មាត្រា ១៤ នៃ ICCPR អនុវត្តបាននៅ អ.វ.ត.ក ។

[12] សំណើសុំដាក់សារណារបស់សហចៅក្រមស៊ើបអង្កេត ត្រង់កថាខណ្ឌ ៥ *យោងពី* ដីកាសម្រេចលើញត្តិរបស់ តា អាន ស្នើសុំធ្វើមោឃភាពនៃកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង ធ្វើនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ត្រង់កថាខណ្ឌ ២៧-២៨។

៨. ដោយពិចារណាលើភស្តុតាងទាំងអស់ដែលប្រមូលបានមកទល់នឹងពេលបច្ចុប្បន្ន វាបានបង្ហាញយ៉ាងល្អិតល្អន់ថា អ្នកស្រី អ៊ឹម ចែម មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ឬជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឡើយ ផ្អែកលើហេតុផលទាំងឡាយដែលយើងខ្ញុំនឹងលើកបង្ហាញនៅទំព័រខាងក្រោម[13]។ ដោយសារកិច្ចស៊ើបសួរ "នឹងជិតចប់សព្វគ្រប់"[14] ដូច្នេះ វាជាការមិនទំនងឡើយដែលថាភស្តុតាងថ្មីៗនឹងត្រូវបានរកឃើញ ហើយដែលភស្តុតាងទាំងនោះ អាចនឹងទុកជាអសារឥតការចំពោះការសន្និដ្ឋាននេះ។ ដើម្បីឱ្យមានប្រសិទ្ធភាព ក្រុមការពារក្តីបានផ្តោតការវិភាគរបស់ខ្លួនទៅលើភស្តុតាងមួយចំនួនទាក់ទងនឹងឧក្រិដ្ឋកម្មទាំងឡាយណា ដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ឱ្យស្ថិតក្រោមពិនិត្យ*ដោយកំបាំងមុខ* កាលពីថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥[15]។ ទោះយ៉ាងណាក្តី ក្រុមការពារក្តីសូមរក្សាសិទ្ធិដើម្បីដាក់ទឡ្ហីករណ៍បន្ថែមលើបញ្ហានេះ ក្នុងករណីដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់លើបទឧក្រិដ្ឋដទៃផ្សេងទៀត។

## ខ. បទដ្ឋានស្តីពីការបង្ហាញភស្តុតាង និងភស្តុតាងដែលតម្រូវក្នុងការចាត់ទុកថាតើជនត្រូវចោទគឺជា "មេដឹកនាំជាន់ខ្ពស់" ឬ ជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"

៩. នៅក្នុងសំណើសុំឱ្យភាគីដាក់សារណា សហចៅក្រមស៊ើបអង្កេតបានគូសបញ្ជាក់ថា ពួកគាត់ "អាចស្នើសុំពីភាគីនានា នូវសារណាទាំងឡាយដែលអាចនឹងជួយបំភ្លឺ"[16] ថាតើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានចាត់ទុកជា "មេដឹកនាំជាន់ខ្ពស់" ម្នាក់ និង/ឬ ជាបុគ្គលម្នាក់ស្ថិតក្នុងចំណោមជនទាំង

---

[13] *សូមមើលផ្នែកខាងក្រោម* ត្រង់កថាខណ្ឌ ១២-៥៧។

[14] សំណើសុំដាក់សារណារបស់សហចៅក្រមស៊ើបអង្កេត ត្រង់កថាខណ្ឌ ៦។

[15] *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹង[អ្នកស្រី] អ៊ឹម ចែម ចុះនៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D239.1។ ក្រុមការពារក្តីកត់សម្គាល់ឃើញថា នីត្យានុកូលភាពនៃដីកាសម្រេចដាក់អ្នកស្រី អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* កំពុងត្រូវបានវិនិច្ឆ័យនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ធ្វើនៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥, ឯកសារ D239/1/2។

[16] សំណើសុំដាក់សារណារបស់សហចៅក្រមស៊ើបអង្កេត ត្រង់កថាខណ្ឌ ៧។

ឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ឬ យ៉ាងណា។ ដោយពិចារណាទៅលើពាក្យពេចន៍នៃសំណើសុំឱ្យភាគីដាក់សារណានេះ ដែលហាក់ដូចជាមិនបានពិចារណាអំពីលទ្ធភាពដែលអ្នកស្រី អ៊ឹម ចែម មិនស្ថិតក្នុងចំណោមបុគ្គលទាំងពីរប្រភេទខាងលើនោះទេ ក្រុមការពារក្ដីយល់ឃើញថា ចំណាត់ការនេះ បង្កើតបានជាជំហានដំបូងនៃដំណើរការបញ្ជូនរឿងទៅជំនុំជម្រះ។

១០. ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតត្រូវតែអនុវត្តនូវបទដ្ឋានភស្តុតាងដែលមានជាអតិបរមា ក្នុងការសម្រេចថាតើអ្នកស្រី អ៊ឹម ចែម ជា "មេដឹកនាំជាន់ខ្ពស់" ឬ ជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដូចដែលត្រូវបានអនុវត្តក្នុងការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះដូច្នោះដែរ។ ក្នុងកម្រិតអប្បបរមា ភស្តុតាងនេះត្រូវតែជាភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់ ដូចដែលបានតម្រូវក្នុងនីតិវិធីសម្រាប់ធ្វើការចោទប្រកាន់[17]។ ទោះជាយ៉ាងណាក៏ដោយ បទដ្ឋានសមស្របមួយ គឺជាបទដ្ឋានដែលមានចែងក្នុងសំណុំរឿង០០២ ទាក់ទងនឹងលក្ខខណ្ឌសម្រាប់ធ្វើការបញ្ជូនរឿងទៅជំនុំជម្រះ ពោលគឺថា ភស្តុតាងត្រូវតែ "មានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឱ្យមានតម្លៃជាភស្តុតាងបន្ទាល់ (ភស្តុតាងដែលត្រូវយកជាបានការរហូតដល់មានភស្តុតាងផ្ទុយ)"[18]។ បទដ្ឋានទាំងពីរគូសបញ្ជាក់អំពីសេចក្ដីតម្រូវឱ្យភស្តុតាងមានភាពស៊ីសង្វាក់ ឬមានការបញ្ជាក់ពីទម្ងន់នៃភស្តុតាង មានន័យថា ភស្តុតាងណាដែលមិនត្រូវបានបញ្ជាក់ពីស្ថានទម្ងន់របស់វាទេនោះ នឹងគ្មានតម្លៃគ្រប់គ្រាន់ដើម្បីបង្ហាញថាតើអ្នកស្រី អ៊ឹម ចែម ស្ថិតក្នុងប្រភេទបុគ្គលណាមួយក្នុងចំណោមបុគ្គលទាំងពីរប្រភេទនេះឡើយ។ ដូច្នេះ សំណួរគឺថា តាមរយៈការថ្លឹងថ្លែងអំពីភាពអាចទៅរួច តើអ្នកស្រី អ៊ឹម ចែម គឺជា "មេដឹកនាំជាន់ខ្ពស់" ឬ ជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះបទឧក្រិដ្ឋកម្មក្នុងក្របខណ្ឌដូចមានចែងក្នុងកិច្ច

---

[17] *សូមមើល* វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩) ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ (វិសោធនកម្មនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥) ។

[18] *សំណុំរឿងលោក នួន ជា និងអ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អ.វ.ត.ក/ក.ស.ច.ស, ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D427 ("ដីកាដំណោះស្រាយនៃសំណុំរឿង០០២") ត្រង់កថាខណ្ឌ ១៣២៣។

ព្រមព្រៀងឬទេ ។

១១. ក្នុងការវាយតម្លៃលើភស្តុតាង ក្រុមការពារក្តីយើងខ្ញុំមិនទទួលយកឡើយនូវភស្តុតាងទាំងឡាយដែលនឹងយកមកពិភាក្សានៅផ្នែកខាងក្រោមនៃការសង្កេតនេះ ចំពោះហេតុផលដែលថាភស្តុតាងទាំងនេះបានបង្ហាញ ឬ ថាអាចជឿជាក់បានជាស្ថាពរហើយ។ ភាពជឿជាក់បាន ឬ មិនបាន វាជាករណី ដែលត្រូវបម្រុងទុកដើម្បីធ្វើការជជីកដេញដោលក្នុងដំណាក់កាលនីតិវិធីសវនាការ នៅពេលដែលអង្គសេចក្តីនៃសំណុំរឿងប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ទាំងមូលត្រូវបានពិចារណា។

## III. សេចក្តីសង្កេត

### ក. អ្នកស្រី អ៊ឹម ចែមមិនមែនជា "មេដឹកនាំជាន់ខ្ពស់"

១២. ពាក្យថា "មេដឹកនាំជាន់ខ្ពស់" រាប់បញ្ចូលតែមេដឹកនាំថ្នាក់កំពូលនៃរបបខ្មែរក្រហមប៉ុណ្ណោះ ដែលពាក្យនេះ មិនបានរាប់បញ្ចូលទាំងអ្នកស្រី អ៊ឹម ចែម ឡើយ។ ក្នុងលក្ខណៈជាសន្ធិសញ្ញាទ្វេភាគី កិច្ចព្រមព្រៀងត្រូវតែបកស្រាយឲ្យស្របតាមអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា[19]។ អត្ថន័យទូទៅនៃពាក្យ "មេដឹកនាំជាន់ខ្ពស់"[20] គឺមានភាពមិនច្បាស់លាស់គ្រប់គ្រាន់ក្នុងការធានានូវការអាស្រ័យលើនៅពេលមានបញ្ហាចោទសួរ ដោយយោងតាមមាត្រា៣២នៃអនុសញ្ញាទីក្រុងវីយែន គឺតម្រូវឲ្យមើលផងដែរនូវប្រវត្តិដើមចមនៃកិច្ចចរចាអំពីកិច្ចព្រមព្រៀង ដើម្បីអាចធ្វើឲ្យយល់ដឹងកាន់តែច្បាស់ពីអត្ថន័យនោះ ។ ប្រវត្តិនៃកិច្ចចរចាបង្ហាញថា ភាគីនៃកិច្ចព្រមព្រៀងមានបំណងចង់ឲ្យ "មេដឹកនាំជាន់ខ្ពស់" ដោយរាប់បញ្ចូលទាំងសមាជិកនៃគណៈអចិន្ត្រៃយ៍ និង គណៈមជ្ឈិម ដែលស្ថិតក្រោមបង្គាប់ ព្រមទាំងអ្នកទាំងឡាយដែលមានឋានៈជារដ្ឋមន្ត្រីក្រោមរបបកម្ពុជា

[19] *សូមមើល* មាត្រា ២(២) នៃកិច្ចព្រមព្រៀង ។

[20] មាត្រា ១ នៃកិច្ចព្រមព្រៀង ។

ប្រជាធិបតេយ្យ[21]។ ចំណុចនេះ ត្រូវបានបង្ហាញក្នុងសំណុំរឿង០០២ នាពេលដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនលោក នួន ជា លោក អៀង សារី លោក ខៀវ សំផន និង លោកស្រី អៀង ធីរិទ្ធ ទៅជំនុំជម្រះ ក្រោមការបញ្ជាក់ថា ពួកគាត់មានលក្ខណៈសម្បត្តិស្ថិតក្នុងប្រភេទដូចបានរៀបរាប់ខាងលើ[22]។

១៣. ដូចដែលសហចៅក្រមស៊ើបអង្កេតបានពន្យល់ក្នុងសំណុំរឿង០០២ ដូច្នេះថា កម្ពុជាប្រជាធិបតេយ្យមានរចនាសម្ព័ន្ធជាសណ្ឋានសាជីជ្រុង៖

> របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបែងចែកជាផ្នែកតូចៗទៅជាអង្គភាពរដ្ឋបាល ដែលមានឋានានុក្រមបន្តគ្នា ទាក់ទងទៅនឹងសង្វាក់នៃការបញ្ជាតាមខ្សែបណ្តោយ (ខ្សែឈរ) ដែលគ្រប់គ្រងដោយមជ្ឈិម។ "*ភូមិភាគ*" ធំៗមួយចំនួនគឺស្ថិតនៅក្រោមមជ្ឈិមដោយផ្ទាល់។ "*ភូមិភាគ*" ទាំងនេះត្រូវបានបែងចែកទៅជា "*តំបន់*" ដែលតំបន់នីមួយៗមានបែងចែកជា "*ស្រុក*" មួយចំនួន ដែលនៅក្នុងស្រុកនីមួយៗមាន "*ឃុំ*" និង "*សហករណ៍*"[23]។

១៤. ក្នុងឋានៈជាលេខាស្រុកដែលត្រូវបានចោទប្រកាន់ អ្នកស្រី អ៊ឹម ចែម មិនមែនជាសមាជិកគណៈ

---

[21] *សូមមើល* អត្ថបទរបស់ S. Heder ស្តីពី "ការពិនិត្យអំពីកិច្ចចរចាឈានទៅដល់ការបង្កើតយុត្តាធិការលើបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះផ្សាយនៅគេហទំព័ររបស់ Cambodia Tribunal Monitor នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១១។ អាចរកមើលបាន:http://www.cambodiatribunal.org/sites/default/files/A%20Review%20of%20the%20Negotiations%20Leading%20to%20the%20Establishment%20of%20the%20Personal%20Jurisdiction%20of%20the%20ECCC.pdf, ចូលពិនិត្យលើកចុងក្រោយនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ ("ការពិនិត្យប្រវត្តិនៃកិច្ចចរចារបស់ Heder) ត្រង់ទំព័រ ៤១។

[22] *សូមមើល* ដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ត្រង់កថាខណ្ឌ ៨៦៩-៧២ (ដែលលើកឡើងថា នួន ជា ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍)។ កថាខណ្ឌលេខ ១០០១-០៤ (ដែលលើកឡើងថា អៀង សារី ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍)។ កថាខណ្ឌលេខ ១១៣១-៣៣ (ដែលលើកឡើងថា ខៀវ សំផន ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងជាសមាជិកសក្តានុពលនៃគណៈអចិន្ត្រៃយ៍)។ កថាខណ្ឌលេខ ១២១៣-១៤ (ដែលលើកឡើងថា អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចក្រោមរបបកម្ពុជាប្រជាធិបតេយ្យ)។ *សូមមើលផងដែរ* ដីកាដំណោះស្រាយនៃសំណុំរឿង០០២ ត្រង់កថាខណ្ឌ ១៣២៧ (ដែលបានសន្និដ្ឋានថាកិច្ចស៊ើបសួរបង្ហាញថាជនត្រូវចោទទាំងបួនរូប គឺជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារអំណាចឋានានុក្រម *ស្របច្បាប់* និង *ជាក់ស្តែង*របស់ពួកគាត់)។

[23] ដីកាដំណោះស្រាយនៃសំណុំរឿង០០២ ត្រង់កថាខណ្ឌ ៦៤។

មជ្ឈិម ឬ គណៈអចិន្ត្រៃយ៍នោះទេ ហើយអ្នកស្រីក៏គ្មានឋានៈជារដ្ឋមន្ត្រីដែរ។ អ្នកស្រី គឺជាកម្មាភិបាលថ្នាក់ទាបក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ពោលគឺ ស្ថិតនៅក្រោមមជ្ឈិមបក្សចំនួនបីថ្នាក់ ហេតុដូច្នេះ អ្នកស្រីពុំស្ថិតក្នុងប្រភេទ "មេដឹកនាំជាន់ខ្ពស់" ឡើយ។ សហចៅក្រមស៊ើបអង្កេតនឹងមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានសមហេតុសមផលឡើយ ប្រសិនបើអ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ឲ្យស្ថិតក្រោមការស៊ើបអង្កេតដោយផ្អែកលើមូលហេតុដែលថាអ្នកស្រីជាមេដឹកនាំជាន់ខ្ពស់មួយរូបនោះ។

## ខ. អ្នកស្រី អ៊ឹម ចែម មិនស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"

### *ខ.១. និយមន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"*

១៥. កិច្ចព្រមព្រៀងពុំបានពង្រីកការបរិយាយអំពីនិយមន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះទេ ដោយបន្សល់ទុកន័យដ៏សាមញ្ញនៃពាក្យនេះ សម្រាប់បង្ហាញពីអំពីឆន្ទានុសិទ្ធិនៃកិច្ចស៊ើបសួរ។ ស្របតាមគោលការណ៍នៃការបកស្រាយដូចបានពិភាក្សានៅក្នុងកថាខណ្ឌ១២ខាងលើ ប្រវត្តិចរចានៃកិច្ចព្រមព្រៀងគួរតែអាចអាស្រ័យលើបាន ដើម្បីបង្ហាញថា តើភាគីនានាចង់មានន័យដូចម្តេចចំពោះពាក្យនេះ។

១៦. ដំបូងឡើយ ភាគីនៃកិច្ចព្រមព្រៀង បានរំពឹងថា មានតែមេដឹកនាំខ្មែរក្រហមមួយក្តាប់តូចប៉ុណ្ណោះនឹងត្រូវយកមកជំនុំជម្រះ[24]។ បន្ទាប់មក គោលបំណងនៃអំណាចរបស់ អ.វ.ត.ក ត្រូវបានពង្រីកតាមរយៈការបូកបញ្ចូល ឧុច ជាគោលដៅនៃការចោទប្រកាន់។ ក្រុមអ្នកជំនាញមួយក្រុមត្រូវបានតែងតាំងដើម្បីវាយតម្លៃលើភស្តុតាងដែលមានស្រាប់ ក្នុងករណីរំលោភសិទ្ធិមនុស្សនាសម័យខ្មែរក្រហម[25]។ ក្រុមនេះបានផ្តល់អនុសាសន៍ថា ការផ្តោតទៅលើការចោទប្រកាន់ គួរធ្វើ

---

[24] *សូមមើល* ការពិនិត្យអំពីប្រវត្តិនៃការចរចាដោយ Heder ត្រង់ទំព័រ ៤១។

[25] "សេចក្តីសម្រេចអនុម័តដោយអង្គមហាសន្និបាតស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" ឯកសាររបស់អង្គការសហប្រជាជាតិ ("អ.ស.ប") លេខ A/RES/52/135 ធ្វើនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៧ ត្រង់កថាខណ្ឌ ១៦។

ហួសពីមេដឹកនាំជាន់ខ្ពស់ និងអាចរាប់បញ្ចូល "មេដឹកនាំមួយចំនួនពីថ្នាក់ភូមិភាគ ព្រមទាំងមន្ត្រីមួយចំនួននៃមន្ទីរសន្តិសុខ ដែលមានមុខងារជាអ្នកសួរចម្លើយ និងធ្វើទារុណកម្ម ដូចជានៅទួលស្លែង"[26] ដែលជាការសំដៅជាក់លាក់ទៅ ឌុច ។ ឌុច បានក្លាយជា "មុខសញ្ញាយោង"[27] ដើម្បីកំណត់គោលដៅនៃការចោទប្រកាន់ក្រោមប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ ថ្វីបើ ឌុច គ្មានឋានៈជាថ្នាក់ដឹកនាំជួរមុខក្នុងបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏គាត់ត្រូវបានចាត់ទុកជា "អ្នកទទួលខុសត្រូវខ្ពស់ចំពោះការសម្លាប់រង្គាលជាទ្រង់ទ្រាយធំ" ហើយបើសិនជាគាត់មិនត្រូវបានចោទប្រកាន់ទេនោះ នឹងមាន "សំណួរចោទឡើង" មិនខានឡើយ[28]។ ត្រង់ប្រការនេះ អ្នកតាក់តែងកិច្ចព្រមព្រៀងមានបំណងកំណត់អាណត្តិរបស់ អ.វ.ត.ក ត្រឹម "បុគ្គល ទាំងឡាយណាដូចជា ឌុច ដែលអាចមិនមែនជាបុគ្គលម្នាក់ស្ថិតក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ឃោរឃៅជាទ្រង់ទ្រាយធំ"[29]។ អ្នកតាក់តែងកិច្ចព្រមព្រៀងប្រាកដជាចាប់អារម្មណ៍តែទៅលើ "មន្ត្រីថ្នាក់កំពូលដូចជា ឌុច ជាបុគ្គលម្នាក់ដែលមានមុខងារយ៉ាងសំខាន់នៅក្នុងសកម្មភាពឃោរឃៅមួយចំនួន"[30]។

១៧. ដើម្បីសម្រួចអាណត្តិរបស់ អ.វ.ត.ក បន្ថែមទៀតឲ្យស្របជាមួយគោលបំណងជាសារវ័ន្ត ក្រុមអ្នកជំនាញបានបង្រួមវិសាលភាពនៃបទឧក្រិដ្ឋកម្ម និងបានផ្តល់អនុសាសន៍ថា អ.វ.ត.ក គួរផ្តោតទៅ

---

[26] "របាយការណ៍របស់អ្នកជំនាញសម្រាប់កម្ពុជាដែលត្រូវបានបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចរបស់អង្គមហាសន្និបាត 52/135" ឯកសាររបស់ អ.ស.ប លេខ A/53/850-S/1999/231 ធ្វើនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ("របាយការណ៍របស់ក្រុមអ្នកជំនាញ") ត្រង់កថាខណ្ឌ ១០៩។

[27] អត្ថបទរបស់ D. Scheffer ស្តីពី "ប្រវត្តិនៃការចរចាអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក" ចុះផ្សាយក្នុងគេហទំព័ររបស់ Cambodia Tribunal Monitor នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១១ ដែលរកមើលបាន: http:www.cambodiatribunal.org/sites/default/files/ctm_blog 5-22-2011.pdf បានចូលពិនិត្យជាលើកចុងក្រោយនៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ ("ប្រវត្តិនៃការចរចាអំពីយុត្តាធិការបុគ្គលដោយ Scheffer") ត្រង់ទំព័រ ៤។

[28] ការពិនិត្យអំពីប្រវត្តិនៃការចរចាដោយ Heder ត្រង់ទំព័រ ២៧។

[29] ប្រវត្តិនៃការចរចាអំពីយុត្តាធិការបុគ្គលដោយ Scheffer ត្រង់ទំព័រ៤។

[30] ប្រវត្តិនៃការចរចាអំពីយុត្តាធិការបុគ្គលដោយ Scheffer ត្រង់ទំព័រ៥។

លើ "បុគ្គលទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"[31]។ ត្រង់នេះ អ្នកជំនាញចង់សំដៅដល់ការរាប់បញ្ចូល "មេដឹកនាំជាន់ខ្ពស់" និង "បុគ្គលថ្នាក់ក្រោមទាំងឡាយ ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់នៅក្នុងអំពើឃោរឃៅធ្ងន់ធ្ងរបំផុត"[32]។ ជាថ្មីម្តងទៀត ឌុច ត្រូវបានប្រើប្រាស់ជាមុខសញ្ញាយោងដើម្បីបង្ហាញថា តើមានអតីតខ្មែរក្រហមណាខ្លះស្ថិតក្នុងប្រភេទចុងក្រោយនេះ[33]។

១៨. ជារួម ទោះបីជាពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គ្មាននិយមន័យច្បាស់លាស់ក៏ដោយ ក៏ពាក្យនេះមានចេតនាសំដៅរាប់បញ្ចូលតែទៅលើអ្នកទទួលខុសត្រូវខ្ពស់បំផុត នូវអំពើឃោរឃៅបំផុតប្រព្រឹត្តដោយខ្មែរក្រហមតែប៉ុណ្ណោះ។ និយមន័យនេះ រួមបញ្ចូលនូវលក្ខខណ្ឌវិនិច្ឆ័យត្រួតចំនួន២ *នោះគឺ* ស្ថានទម្ងន់នៃបទឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ចារីទាក់ទងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះ[34]។ ដោយយោងលើការលើកឡើងខាងលើ ពាក្យនេះមានន័យថា៖

- ជនទាំងឡាយណាដែលទទួលខុសត្រូវលើ *ការប្រព្រឹត្តជាទ្រង់ទ្រាយធំនៃឧក្រិដ្ឋកម្មដ៏ឃោរឃៅ*[35]
- *មន្ត្រីថ្នាក់កំពូល* ដូចជា ឌុច ដែលជាបុគ្គលមាន*តួនាទីសំខាន់ក្នុងការប្រព្រឹត្តអំពើឃោរឃៅ*[36]

---

[31] របាយការណ៍របស់ក្រុមអ្នកជំនាញ ត្រង់កថាខណ្ឌ ១១០ និង ១៥៤។

[32] របាយការណ៍របស់ក្រុមអ្នកជំនាញ ត្រង់កថាខណ្ឌ ១១០ (សេចក្តីបញ្ជាក់បន្ថែម)។

[33] ការពិនិត្យអំពីប្រវត្តិនៃការចរចាដោយ Heder ត្រង់ទំព័រ ២៧។

[34] *សូមមើល សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច,* សំណុំរឿង ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សាលក្រម, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារ E188 ("សាលក្រម*ឌុច*") ត្រង់កថាខណ្ឌ ២២។ *សំណុំរឿងរបស់លោក មាស មុត,* ០០៣/០៧ កញ្ញា ២០០៩/អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើយុត្តាធិការបុគ្គល និងគោលការណ៍ស៊ើបសួរទាក់ទងជនសង្ស័យ [កោសលប់] ធ្វើនៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២, ឯកសារ D49 ត្រង់កថាខណ្ឌ ១៥។

[35] ប្រវត្តិនៃការចរចាអំពីយុត្តាធិការបុគ្គលដោយ Scheffer ត្រង់ទំព័រ ៤។

[36] ប្រវត្តិនៃការចរចាអំពីយុត្តាធិការបុគ្គលដោយ Scheffer ត្រង់ទំព័រ ៥។

- បុគ្គល*ថ្នាក់ក្រោម*ទាំងឡាយ នៅពេលណាដែលបុគ្គលទាំងនោះ*ជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងការប្រព្រឹត្តអំពើឃោរឃៅដ៏ធ្ងន់ធ្ងរ*[37]

១៩. ដូចដែលយើងនឹងបង្ហាញខាងក្រោម អ្នកស្រី អ៊ឹម ចែម មិនស្ថិតក្នុងប្រភេទបុគ្គលណាមួយដូចដែលបានរៀបរាប់នេះឡើយ។ អ្នកស្រីគឺជាលេខាស្រុកថ្នាក់ក្រោម ជាលេខាស្រុកមួយរូបក្នុងចំណោមលេខាស្រុកចំនួនជាងមួយរយរូបនៅទូទាំងប្រទេសក្នុងអំឡុងរបបខ្មែរក្រហម[38]។ មានតែភស្តុតាងតិចតួច ឬ គ្មានសោះចំពោះបទឧក្រិដ្ឋដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់ ពាក់ព័ន្ធទៅនឹងការដ្ឋានស្ពានស្រែង និងមន្ទីរសន្តិសុខភ្នំទ្រយោង ហើយក៏ស្ទើរតែគ្មានសោះនូវភស្តុតាងស្តីពីការជាប់ពាក់ព័ន្ធរបស់អ្នកស្រីចំពោះឧក្រិដ្ឋកម្មទាំងនោះ ។ នៅពេលដែលភស្តុតាងស្តីអំពីស្ថានទម្ងន់នៃបទឧក្រិដ្ឋ និងកម្រិតនៃការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ដែលរងការចោទប្រកាន់ក្នុងឧក្រិដ្ឋកម្មទាំងនោះត្រូវបានវាយតម្លៃ និងបានប្រៀបធៀបជាមួយ ឌុច ជាបុគ្គលម្នាក់ដែលត្រូវបានចាត់ទុកជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះ វាកាន់តែមានភាពច្បាស់លាស់ថែមទៀត ដែលថាអ្នកស្រី អ៊ឹម ចែម មិនស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក ឡើយ។

### *ខ.២. ការដ្ឋានស្ពានស្រែង*

២០. នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី សហព្រះរាជអាជ្ញាអន្តរជាតិបានចោទប្រកាន់ដូច្នេះថា៖

> នៅក្នុងឆ្នាំ១៩៧៨ មនុស្សចំនួន ១.៣០០ នាក់ ត្រូវបានដាក់ពង្រាយនៅតាមការដ្ឋានធ្វើការ[ដោយ]បង្ខំនៅស្ពានស្រែង និង[នៅ]ការដ្ឋានសាងសង់ទំនប់ព្រៃរនាមនៅក្នុងស្រុកព្រះនេត្រព្រះ (តំបន់៥របស់ភូមិភាគពាយ័ព្យ)។ ការកសាងទំនប់ស្ពានស្រែងប្រវែង៨គីឡូម៉ែត្រត្រូវបានធ្វើឡើងដោយដៃសុទ្ធសាធ និងបានបញ្ចប់ក្នុងរយៈពេល

---

[37] របាយការណ៍របស់ក្រុមអ្នកជំនាញ ត្រង់កថាខណ្ឌ ១១០។

[38] *សូមមើល* ការបរិយាយពី "ខេត្ត ភូមិភាគ តំបន់ និងស្រុកនៃរបបកម្ពុជាប្រជាធិបតេយ្យ" នៅក្នុងទស្សនាវដ្តី*ស្វែងរកការពិត* របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (លេខ១ ខែ មករា ឆ្នាំ ២០០០) ត្រង់ទំព័រ ១៣ ("កម្ពុជាមាន...១១២ ស្រុក")។

បីខែ។ ពលករដោយបង្ខំទាំងអស់ដែលធ្វើការនៅការដ្ឋានសាងសង់ ត្រូវធ្លាក់ខ្លួនឈឺ កង្វះអាហារ និងគ្មានសម្លៀកបំពាក់ត្រឹមត្រូវ។ ការគំរាមសម្លាប់ត្រូវបានធ្វើឡើង តាមទម្លាប់ចំពោះកំហុសតូចតាច ហើយកម្មករទាំងអស់នោះ ត្រូវទទួលរងការចាប់ខ្លួន និងការសម្លាប់[39]។

២១. នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ចៅក្រម Mark B. HARMON ដែលកាលណោះជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ក្នុងឋានៈរបស់អ្នកស្រីជាលេខាស្រុកព្រះនេត្រព្រះចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលបានប្រព្រឹត្តនៅការដ្ឋានស្ពានស្រែងចាប់ពីចន្លោះខែ មេសា ឆ្នាំ ១៩៧៧ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ អ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋកម្មទាំងនេះតាមរយៈការប្រព្រឹត្ត (បទល្មើសសហចារី) ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងការជំរុញ និងតាមរយៈការទទួលខុសត្រូវកម្រិតខ្ពស់[40]។

២២. ក្រុមការពារក្តីកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់ការបញ្ជាក់បំភ្លឺអំពីវិសាលភាពអ្វីនៅ "ការដ្ឋានស្ពានស្រែង" ឡើយ។ "ទំនប់ស្ពានស្រែង និងទំនប់ព្រៃរនាម" ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានពិពណ៌នា[41] ស្របគ្នាទៅនឹងអ្វីដែលអ្នកស៊ើបអង្កេតបានហៅថា "ប្រឡាយស្ពានស្រែង" និង "អាងស្តុកទឹកព្រៃរនាម" នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ពួកគាត់។ កាលពីដំបូង អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានកំណត់ថា ប្រឡាយស្ពានស្រែងគិតចាប់ពីស្ទឹងស្ពានស្រែងនៅក្នុងស្រុកភ្នំស្រុក ទៅដល់អាងស្តុកទឹកព្រៃរនាមស្ថិតតាមបណ្តោយផ្លូវ

[39] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៩ (ឯកសារយោងត្រូវបានលុបចោល)។

[40] *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹង [អ្នកស្រី] អ៊ឹម ចែម ធ្វើនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥, ឯកសារ D239.1។

[41] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៩។

ជាតិលេខ៦ នៃស្រុកព្រះនេត្រព្រះ[42]។ ពួកគាត់បានវាយតម្លៃប្រឡាយនេះថាមានបណ្ដោយប្រវែងប្រមាណ ៨ ទៅ ១០ គីឡូម៉ែត្រ និងមានទទឹង១៥ម៉ែត្រ[43]។ សាក្សីមួយចំនួនក៏បានពិពណ៌នាអំពីប្រឡាយស្ពានស្រែងដូច្នេះដែរ[44]។ អ្នកស្រី អ៊ឹម ចែម ក៏បានពិណ៌នាដូចគ្នានេះដែរ[45]។ យោងតាមសាក្សី កោ ឡិន នៅប៉ែកខាងត្បូងនៃប្រឡាយស្ពានស្រែងដែលគិតចាប់ពីផ្លូវជាតិលេខ៦ និងភ្ជាប់ទៅអាងស្តុកទឹកព្រៃរនាមត្រូវបានគេហៅថា "ប្រឡាយអូរលៀប"[46]។

២៣. វាជាការសមហេតុផលក្នុងការពិចារណាថាសហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើឲ្យសហចៅក្រមស៊ើបអង្កេតស៊ើបទៅលើទីតាំងឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ ក្រោមការចង្អុលបង្ហាញថា ជា "ទំនប់ស្ពានស្រែង និង ទំនប់ព្រៃរនាម" ឬ "ប្រឡាយស្ពានស្រែង" ឬ "ប្រឡាយអូរលៀប" ។ ធ្វើដូចនេះ គឺបង្កើតឲ្យមានភាពសមទំនងដើម្បីធ្វើការសន្និដ្ឋានថា ការលើកឡើងអំពី "ការដ្ឋានស្ពានស្រែង" នៅក្នុងការជូនដំណឹងអំពីការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម[47] មានការទាក់ទងគ្នាទៅនឹងព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅ "ទំនប់ស្ពានស្រែង និងទំនប់ព្រៃរនាម" ដែលភ្ជាប់

[42] របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ធ្វើនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/19 ត្រង់ទំព័រ ២។ *សូមមើលផងដែរ* ផែនទីនៃទីតាំងស្ពានស្រែង និងទំនប់ស្តុកទឹកព្រៃរនាម ក្នុងតំបន់ ៥ នៃភូមិភាគពាយ័ព្យ ធ្វើនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/19.4។

[43] របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ធ្វើនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/19 ត្រង់ទំព័រ ២។

[44] *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់សាក្សី គក់ ប៊ុយ ធ្វើនៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/9 ត្រង់ទំព័រ ៥។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់សាក្សី កោ ឡិន ធ្វើនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/98 ត្រង់ទំព័រ ៩។

[45] *សូមមើល* ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់អ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4 ត្រង់ទំព័រ ៥-៦ (ដែលពិពណ៌នាអំពីស្ពានស្រែង និងទំនប់ស្តុកទឹកព្រៃរនាម ថាភ្ជាប់ដោយប្រឡាយបណ្ដោយដប់គីឡូម៉ែត្រ និងទទឹងសាមសិបម៉ែត្រ)។ កិច្ចសម្ភាសន៍របស់ផលិតកម្ម Smiling Toad ជាមួយអ្នកស្រី អ៊ឹម ចែម នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, ឯកសារ D1.3.12.1 ត្រង់ទំព័រ ១៧ និង ២០ (ដែលពិពណ៌នា "ទំនប់*យាយ*ចែម" ឬ "ប្រឡាយ*យាយ*ចែម" ថាជាប្រឡាយបណ្ដោយប្រាំបីគីឡូម៉ែត្រ និងទទឹងសាមសិបម៉ែត្រ ដោយភ្ជាប់ស្ពានស្រែងទៅនឹងរនាម)។

[46] កំណត់ហេតុនៃកិច្ចស៊ើបសួរ ធ្វើនៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/129 ត្រង់ទំព័រ ២។

[47] *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D239.1។

ដោយ "ប្រឡាយស្ពានស្រែង" និង "ប្រឡាយអូរលៀប"។

## ស្ថានទម្ងន់នៃបទឧក្រិដ្ឋ

២៤. ស្ថានទម្ងន់នៃបទឧក្រិដ្ឋដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់នៅការដ្ឋានស្ពានស្រែងអាចត្រូវបានកំណត់ដោយផ្អែកលើកត្តាមួយចំនួន ដូចជា ចំនួនជនរងគ្រោះ វិសាលភាពភូមិសាស្ត្រ និងវិសាលភាពពេលវេលាដែលបទឧក្រិដ្ឋមួយចំនួនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ព្រមទាំងចំនួនព្រឹត្តិការណ៍ឧប្បត្តិហេតុដាច់ដោយឡែកផ្សេងៗទៀត[48]។ មានការវិភាគមួយលើភស្តុតាងពាក់ព័ន្ធនឹងការដ្ឋានស្ពានស្រែងបានបង្ហាញឲ្យឃើញថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ មិនអាចបំពេញនូវលក្ខខណ្ឌនៃស្ថានទម្ងន់ដែលតម្រូវដោយប្រភេទនៃ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ទេ។

២៥. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា កម្មករនៅការដ្ឋានស្ពានស្រែង "ធ្លាក់ខ្លួនឈឺ កង្វះខាតអាហារ គ្មានសម្លៀកបំពាក់ត្រឹមត្រូវ"[49] និងបានទទួលរងនូវការ "គំរាមសម្លាប់...ចំពោះកំហុសតូចតាច"[50] ព្រមទាំង "ទទួលរងការចាប់ខ្លួន និងការយកទៅសម្លាប់"[51]។ ការចោទប្រកាន់ទាំងនេះគឺផ្អែកតែទៅលើកិច្ចសម្ភាសន៍ចំនួនពីររបស់អ្នកស្រី អ៊ឹម ចែម ដែលបានផ្តល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") និង ផលិតកម្ម Smiling Toad ព្រមទាំងកិច្ចសម្ភាសន៍របស់សាក្សី តក់ ប៉ុយ ជាមួយ DC-Cam ដែលកិច្ចសម្ភាសន៍ទាំងនេះ គ្មានមួយណាត្រូវបានធ្វើឡើងដោយមានការធ្វើសច្ចាប្រណិធានឡើយ។

---

[48] កថាខណ្ឌ ២២ នៃសាលក្រម *ឌុច*។

[49] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៩ *យោង* ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម កាលពីថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4 ត្រង់ទំព័រ ៦ និង ៩។

[50] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៩ *យោងពី* ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ តក់ ប៉ុយ នៅថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.11.52 ត្រង់ទំព័រ ១៦។

[51] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៩ *យោង* ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម កាលពីថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4 ត្រង់ទំព័រ ៧។

២៦. កិច្ចសម្ភាសន៍ទាំងនេះដែលសហព្រះរាជអាជ្ញាអន្តរជាតិលើកយកមកធ្វើជាសំអាង គឺមិនពាក់ព័ន្ធទាល់តែសោះនឹងការដ្ឋានស្ពានស្រែង។ ចម្លើយរបស់សាក្សី តក់ ប៊ុយ ដែលថាកម្មករទទួលរងការគំរាមសម្លាប់តាមទម្លាប់ចំពោះកំហុសតូចតាច គឺទាក់ទងព្រឹត្តិការណ៍នានានៅទំនប់ត្រពាំងថ្ម[52]។ ចម្លើយរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងបទសម្ភាសន៍ជាមួយ DC-Cam ពាក់ព័ន្ធនឹងត្រង់ចំណុចដែលអ្នកស្រីថ្លែងថា មានប្រជាជនខ្លះត្រូវបានរងការចាប់ខ្លួន និង យកទៅសម្លាប់ ព្រមទាំងធ្លាក់ខ្លួនឈឺ កង្វះខាតអាហារ និងគ្មានសម្លៀកបំពាក់ត្រឹមត្រូវ គឺជាការបរិយាយពីទិដ្ឋភាពនៃស្រុកព្រះនេត្រព្រះនៅពេលអ្នកស្រីទៅដល់[53]។ មិនមានប្រភពសំអាងជាមូលដ្ឋានផ្លូវច្បាប់ណាមួយដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងទាក់ទងនឹងអំពើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅការដ្ឋានស្ពានស្រែងនៅពេល ឬ ក្រោយពេលអ្នកស្រី អ៊ឹម ចែម បានក្លាយជាលេខាស្រុកព្រះនេត្រព្រះឡើយ។ អ្នកស្រី អ៊ឹម ចែម គ្រាន់តែបានលើកឡើងពីបញ្ហារបស់ប្រជាជនដែលបាន និងកំពុងជួបប្រទះក្នុងស្រុកនេះទាំងមូល[54] នៅពេលអ្នកស្រីបានទៅដល់ និងបានដាក់ផែនការ

---

[52] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ តក់ ប៊ុយ នៅថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.11.52 ត្រង់ទំព័រ ៥-៧ និងទំព័រ ១៥-១៦។

[53] *សូមមើលឧទាហរណ៍* ប្រតិចារឹកកិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4 ត្រង់ទំព័រ ៩ ("ហើយខ្ញុំទៅដល់កន្លែងនោះ មើលទៅវាវេទនាហ្មង វេទនាត្រង់ថា យុវជនយុវនារីតាមការដ្ឋាន ...ដែលឈឺហ្នឹង ស្គមស្គាំង...ឈឺដេកនៅលើផ្ទះហ្នឹង មើលទៅអត់មានស្អីទេ...មានដល់ពុលស្លឹកឈើដែលយកទៅស្ល ហូប ។ ហ្នឹងការលំបាករបស់ប្រជាជននៅស្រុកព្រះនេត្រព្រះមុនពេលដែលខ្ញុំទៅ") ត្រង់ទំព័រ ២១ (មុនពេលទៅដល់ព្រះនេត្រព្រះមានការចាប់ប្រជាជន)។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍ធ្វើឡើយដោយផលិតកម្ម Smiling Toad ជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, ឯកសារ D1.3.12.1 ត្រង់ទំព័រ ១១ ("ខ្ញុំទៅដល់ស្រុកព្រះនេត្រព្រះ ចំពេលពិបាកស្រុកមហាលំបាកវេទនា ហើយក្រដាងគេបង្អស់...ឃើញថាប្រជាជនអត់ ក្រគ្មានអីស៊ីមានតែបាតដៃទទេ...ខ្ញុំដើរមើលគ្រប់ភូមភូមិឃុំទាំងអស់ មានប្រាំមួយក្នុងស្រុកព្រះនេត្រព្រះ ឃើញគ្មានស្អីទាំងអស់ សំពត់ អាវក៏គ្មាន") ត្រង់ទំព័រ ១២ ("ដល់អញ្ចឹងមនុស្សឈឺច្រើន ឈឺអស់មួយម៉ឺនហ្នឹង គឺស្លាប់ និងឈឺដាច់ពោះតែម្តង") ត្រង់ទំព័រ ១៥ ("ពេលដែលខ្ញុំទៅដល់ [គេ] ចាប់អ្នកមុនៗហ្នឹងអស់ហើយ មិនដឹងយកទៅណាទេ")។

[54] *សូមមើលឧទាហរណ៍* សេចក្តីរាយការណ៍របស់គណៈតំបន់៥ប្រចាំសប្តាហ៍ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧, ឯកសារ D1.3.10.1 ត្រង់ទំព័រ ១០-១១ (ដែលបញ្ជាក់ការពិតដល់ការពិតណ៍នារបស់អ្នកស្រី អ៊ឹម ចែម អំពីស្រុកព្រះនេត្រព្រះទាក់ទងការខ្វះស្បៀងនៅពេលអ្នកស្រីទើបទៅដល់)។

ដើម្បីដោះស្រាយបញ្ហាទាំងនោះតែប៉ុណ្ណោះ[55]។ ហេតុដូចនេះ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលឡើយ ចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងការដ្ឋានស្ពានស្រែង ដែលមិនត្រូវបានគាំទ្រដោយភស្តុតាងទាំងឡាយ ដែលប្រមូលបានទាំងអម្បាលម៉ានក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរជាងប្រាំមួយឆ្នាំនេះ ។ ប៉ុន្តែអ្វីដែលគួរឱ្យភ្ញាក់ផ្អើលទៅវិញនោះគឺថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបោះបង់ចោលនូវការចោទប្រកាន់ បើទោះបីជាគ្មានភស្តុតាងគាំទ្រនូវការចោទទាំងនេះក៏ដោយ។

២៧. នៅក្នុងសំណុំរឿងវិញទៀតសោត គឺគ្មានអ្វីមានតម្លៃជាភស្តុតាងឡើយដែលបង្ហាញថា មានការប្រព្រឹត្តបទឧក្រិដ្ឋអ្វីនៅការដ្ឋានស្ពានស្រែងឡើយ បន្ទាប់ពីអ្នកស្រី អ៊ឹម ចែម បានទៅដល់ស្រុកព្រះនេត្រព្រះ។ ផ្ទុយទៅវិញ មានភស្តុតាងស៊ីសង្វាក់បង្ហាញថាប្រឡាយស្ពានស្រែងដែលមានបណ្តោយចំនួនប្រាំបីទៅដប់គីឡូម៉ែត្រ ត្រូវបានសង់រួចមុនពេលកម្មាភិបាលភូមិភាគនិរតី និងអ្នកស្រី អ៊ឹម ចែម ទៅដល់ក្នុងភូមិភាគពាយ័ព្យ[56]។ ចំណុចនេះ ត្រូវបានបញ្ជាក់អះអាងដោយចំនួនភាគច្រើននៃចម្លើយរបស់សាក្សី ដែលពួកគាត់បានពិពណ៌នាអំពីព្រឹត្តិការណ៍ផ្សេងៗនៅ

---

[55] *សូមមើលឧទាហរណ៍* ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4 ត្រង់ទំព័រ ៦ ("ខ្ញុំដើរមើលសព្វហើយ ខ្ញុំចែកកម្លាំងជាពីរ [ផ្នែក] ខ្ញុំលើកផែនការមួយ") ត្រង់ទំព័រ ៩ (ខ្ញុំបានស្នើទៅភ្នំពេញថាប្រជាជនខ្ញុំខ្វះសម្លៀកបំពាក់...ខ្ញុំបានបង្កើតកន្លែងកាត់ដេរដើម្បីដេរខោអាវឱ្យប្រជាជន) ត្រង់ទំព័រ ១០ ("ប្រជាជនស្លាប់ អត់ពេកទៅ សូម្បីតែជន្លេននោះក៏មិនមានផង...ខ្ញុំទៅដល់ឃើញទិដ្ឋភាពហ្នឹង ខ្ញុំដែលធ្លាប់លំបាកខ្លួនខ្ញុំប្រវត្តិមួយដែលខ្ញុំគ្មានម៉ែ ចឹងខ្ញុំមានការអាណិតអាសូរណាស់ [ទើប] ខ្ញុំដាក់ផែនការភ្លាម") ត្រង់ទំព័រ ១២ ("ហើយខ្ញុំមើលទៅដូចវាលំបាកពេក [ចេះតែមានការចាប់ខ្លួន] ខ្ញុំសុំឱ្យគេដកអាវុធទុក")។ កិច្ចសម្ភាសន៍របស់ផលិតកម្ម Smiling Toad នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, ឯកសារ D1.3.12.1 ត្រង់ទំព័រ ១៤ ("អាវរបស់ [គ្រឿងបរិភោគ] នៅក្នុងឃ្លាំងទាំងប៉ុន្មាន [ខ្ញុំ] ឱ្យបើកទ្វារទាំងអស់")។

[56] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី តក់ ប៊ុយ ធ្វើនៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/9 ត្រង់ទំព័រ ៥។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយសាក្សី តក់ ប៊ុយ ធ្វើនៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D219/422.8 ត្រង់ទំព័រ១៩។ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង ធ្វើនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/19 ត្រង់ទំព័រ ២។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ឆាយ ផាន នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៣, ឯកសារ D119/40 ត្រង់ទំព័រ៥។ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះនៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ D119/129 ត្រង់ទំព័រ ២។

ប្រឡាយស្ពានស្រែង មុនពេលកម្មាភិបាលភូមិភាគនិរតីបានមកដល់[57] ពោលគឺថា ព្រឹត្តិការណ៍នា *ពេលនោះគឺ* មិនស្ថិតក្រោមវិសាលភាពពេលវេលាដែលត្រូវយកមកធ្វើការចោទប្រកាន់មកលើ អ្នកស្រី អ៊ឹម ចែម ឡើយ។ មានការបញ្ជាក់អះអាងបន្ថែមទៀតពីកម្មករនៅស្ពានស្រែង ដោយបាន ថ្លែងឲ្យដឹងថា ពួកគាត់មិនដែលបានឃើញអ្នកស្រី អ៊ឹម ចែម ចុះមកពិនិត្យការងារនៅប្រឡាយ នេះទេ[58] ហើយក៏មិនដែលបានដឹងឮអ្វីអំពីអ្នកស្រីដែរ[59]។

២៨. ទាក់ទងនឹងប៉ែកខាងត្បូងនៃប្រឡាយស្ពានស្រែងគិតចាប់ពីផ្លូវជាតិលេខ៦ សាក្សីខ្លះបាននិយាយថា អ្នកស្រី អ៊ឹម ចែម ជាអ្នកពិនិត្យមើលការងារនៅប្រឡាយអូរលៀប។ ទោះជាយ៉ាងណាក្តី ពួកគាត់ បានឯកភាពជាមួយចម្លើយរបស់អ្នកស្រី អ៊ឹម ចែម ត្រង់ចំណុចដែលថាអ្នកស្រីបានជួយរែកដី កម្មករ[60] ឬ ប្រាប់ពួកគាត់ឲ្យទៅរកម្ហូបអាហារទទួលទាន[61]។ លើសពីនេះ មិនមានភស្តុតាងគួរ

---

[57] *សូមមើលឧទាហរណ៍*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី នៅ ចាត់ នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/130 ត្រង់ទំព័រ ៣០-៣១ (ដែលនិយាយថាគាត់ធ្វើការងារនៅស្ពានស្រែង មុនពេលពួកនិរតីមកដល់)។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី រឹម សឹត នៅថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/10 ត្រង់ទំព័រ៣-៤ (ដែលនិយាយថាគាត់ធ្វើការនៅព្រៃរនាមមុនចូលឆ្នាំខ្មែរឆ្នាំ១៩៧៧)។ កំណត់ហេតុជាលាយលក្ខណ៍ អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ឆាយ ផាន នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៣, ឯកសារ D119/40 ត្រង់ទំព័រ៣ (ដែលនិយាយថា គាត់ធ្វើការនៅស្ពានស្រែង ក្នុងឆ្នាំ១៩៧៥)។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ សាក្សី ក្រូច ទឹម នៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣, ឯកសារ D119/69 ត្រង់ទំព័រ១២ (ដែលនិយាយថា គាត់ធ្វើការនៅការដ្ឋានស្ពាន ស្រែងអំឡុងរដូវប្រាំងដើមឆ្នាំ១៩៧៧)។

[58] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី តក់ ប៉ុយ នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/9 ត្រង់ទំព័រ ៥។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី នៅ ចាត់ នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/130 ត្រង់ទំព័រ ៣៥។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ យ ម៉ុត នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១, ឯកសារ D53 ត្រង់ទំព័រ ៥។

[59] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ យូ មុត នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៤, ឯកសារ D219/1 ត្រង់ទំព័រ ១៦។

[60] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី កោ ឡិន នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/98 ត្រង់ទំព័រ ១០។

[61] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ក្រិត វិត នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣, ឯកសារ D119/42 ត្រង់ទំព័រ ៥។

ជឿជាក់ណាមួយដែលថា មានការចាប់ខ្លួន និង សម្លាប់នៅប្រឡាយអូរលៀបឡើយ បន្ទាប់ពីអ្នកស្រី អ៊ឹម ចែម បានទៅដល់ក្នុងភូមិភាគពាយ័ព្យ ។

២៩. ពាក់ព័ន្ធនឹងវិសាលភាពភូមិសាស្ត្រ និងពេលវេលានៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់លើអ្នកស្រីវិញ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ឧក្រិដ្ឋកម្មទាំងនោះបានកើតឡើងរយៈពេលចំនួន៣ខែ នៅប្រឡាយដែលមានបណ្តោយប្រវែង១០គីឡូម៉ែត្រ និងទទឹងមានប្រវែង១៥ម៉ែត្រ។ ក្នុងករណីនេះ ដោយពិចារណាទៅលើប្រឡាយស្ពានស្រែងដែលមានបណ្តោយប្រមាណពី ៨ ទៅ ១០ គីឡូម៉ែត្រនោះត្រូវបានសាងសង់រួចតាំងពីមុនពេលអ្នកស្រី អ៊ឹម ចែម ទៅដល់ក្នុងស្រុកព្រះនេត្រព្រះ ដូចនេះ វិសាលភាពភូមិសាស្ត្រ និងពេលវេលានៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅប្រឡាយអូរលៀប គឺមានចំនួនពីរគីឡូម៉ែត្រ និងមានរយៈពេលយ៉ាងច្រើនបំផុតចំនួន៣ខែ[62]។ វិសាលភាពនេះ ស្ថិតនៅសែនឆ្ងាយពីលក្ខខណ្ឌភូមិសាស្ត្រ និងពេលវេលាដែលបានកំណត់លើករណីរបស់ ឌុច ដែលត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្មនៅទូទាំងប្រទេស និងបានកើតឡើងអស់រយៈពេលជាង៣ឆ្នាំ[63]។ ដូច្នេះ គេមិនអាចជជែកតតាំងពីវិសាលភាពភូមិសាស្ត្រ និងពេលវេលានៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅការដ្ឋានស្ពានស្រែង ថាអាចបំពេញឲ្យលក្ខខណ្ឌនៃស្ពានទម្ងន់ដើម្បីកំណត់ថាជនណាម្នាក់ស្ថិតក្នុងចំណោមជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដូចដែលអ្នកពង្រាងកិច្ចព្រមព្រៀងមានបំណងតាក់តែងឡើយ ។

---

[62] ការដ្ឋានស្ពានស្រែង បូករួមទាំងប្រឡាយស្ពានស្រែង ចាប់ពីស្ទឹងស្ពានស្រែងក្នុងស្រុកភ្នំស្រុក ប្រឡាយអូរលៀបចាប់ពីប៉ែកខាងត្បូងនៃផ្លូវជាតិលេខ៦ និងអាងស្តុកទឹកព្រៃរនាមក្នុងស្រុកព្រះនេត្រព្រះ។ ដោយហេតុថាអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានវាយតម្លៃការដ្ឋាន នេះថាមានប្រវែង១០គីឡូម៉ែត្រ ហើយថាប្រឡាយស្ពានស្រែងមានប្រវែងប្រមាណ៨ ទៅ១០ គីឡូម៉ែត្រ ប៉ែកខាងត្បូងប្រឡាយនេះ ដែលមានឈ្មោះថា "ប្រឡាយអូរលៀប" និងភ្ជាប់ទៅទំនប់ស្តុបទឹកព្រៃរនាម មានចម្ងាយប្រមាណ ២ គីឡូម៉ែត្រ។ *សូមមើល* របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/19។ កំណត់ហេតុនៃកិច្ចស៊ើបសួរ ធ្វើនៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ D119/129។

[63] សាលដីកា*ឌុច* ត្រង់កថាខណ្ឌ ២-៣។

## កម្រិតនៃការទទួលខុសត្រូវ

៣០. កម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទត្រូវបានវាយតម្លៃដោយផ្អែកលើកម្រិតនៃការចូលរួមរបស់គាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ឋានានុក្រម ឬ តួនាទី ព្រមទាំងភាពអចិន្ត្រៃយ៍នៃតួនាទីនោះ[64]។ ក្នុងការវាយតម្លៃអំពីកម្រិតនៃការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មនានាដែលអាចត្រូវបានប្រព្រឹត្តទៅនៅការដ្ឋានស្ពានស្រែង សហចៅក្រមស៊ើបអង្កេតត្រូវតែពិចារណាអំពីសិទ្ធិអំណាច*ជាក់ស្តែង* និង អំណាច*ផ្លូវច្បាប់*របស់អ្នកស្រី[65]។ ចំណុចនេះ ត្រូវបានពន្យល់ណែនាំនៅក្នុងសំណុំរឿង០០១។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ឌុច "អាចត្រូវបានចាត់ទុកថាចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតលើបទឧក្រិដ្ឋមួយចំនួន...ដោយផ្អែកលើអំណាចឋានានុក្រមជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាព ក៏ដូចជាតាមរយៈការចូលរួមរបស់គាត់ដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងនាមជាអនុលេខា បន្ទាប់មកជាលេខានៃមន្ទីរស២១ ដែលជាមន្ទីរសន្តិសុខស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ពីគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា"[66]។

៣១. សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានយោងលើឯកសារដែលគួរអាចជឿជាក់បានណាមួយដើម្បីអាចបង្ហាញថាអ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាច*ជាក់ស្តែង* ឬ សិទ្ធិអំណាច*ផ្លូវច្បាប់*លើការដ្ឋានស្ពានស្រែងឡើយ ។ សេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម ដែលថាអ្នកស្រីមានគម្រោងសាងសង់ការដ្ឋានស្ពានស្រែង ហើយក្រោយមក អ្នកស្រីក៏បានហៅប្រជាជនឲ្យចូលរួម

---

[64] សាលក្រម *ឌុច* ត្រង់កថាខណ្ឌ ២២។

[65] *សូមមើល សំណុំរឿងរបស់លោក មាស មុត* សំណុំរឿងលេខ ០០៣/០៧ កញ្ញា ២០០៩/អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើយុត្តាធិការបុគ្គល និងគោលការណ៍ស៊ើបសួរទាក់ទងជនសង្ស័យ [កោសលប់] ធ្វើនៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២ឯកសារ D49 ត្រង់កថាខណ្ឌ ២១។

[66] *សំណុំរឿងរបស់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧/អ.វ.ត.ក/ក.ស.ច.ស, ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៨, ឯកសារ D99 ("ដីកាដំណោះស្រាយនៃសំណុំរឿង ០០១") ត្រង់កថាខណ្ឌ ១២៩។

ប្រជុំដើម្បីសុំមតិយោបល់លើបញ្ហានេះ[67] គឺមិនត្រូវបានគាំទ្រដោយភស្តុតាងផ្សេងៗ ដែលប្រមូលបានក្នុងសំណុំរឿងនោះទេ។

៣២. អវត្តមាននៃភាពអាចជឿជាក់បានក្នុងសេចក្តីថ្លែងការណ៍របស់អ្នកស្រីខ្លួនឯង គឺជារឿងគួរឲ្យកត់សម្គាល់ ដោយហេតុថា ទោះបីជាមានការរៀបរាប់យ៉ាងត្រឹមត្រូវអំពីការជីកប្រឡាយ ដូចដែលត្រូវបានកំណត់អត្តសញ្ញាណដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ក៏ដោយ[68] ក៏អ្នកស្រី អ៊ឹម ចែម គឺជាបុគ្គលតែម្នាក់គត់ដែលអះអាងថា ប្រឡាយនេះត្រូវបាន ដាក់ឈ្មោះតាមឈ្មោះរបស់អ្នកស្រី។ សាក្សី ទុំ សឿន និង ឆៅ ចាត់ ជាសាក្សីដែលត្រូវបានសួរនាំថាតើពិតឬទេដែលថាប្រឡាយនោះមាន "ឈ្មោះថា ប្រឡាយ*យាយ*ចែម[?]" សាក្សីទាំងពីរបានបដិសេធថាពួកគាត់មិនដែលធ្លាប់ឮគេហៅឈ្មោះប្រឡាយនេះដូច្នេះឡើយ[69]។ មានតែ អ្នកស្រី អ៊ឹម ចែម ខ្លួនឯងតែប៉ុណ្ណោះ ដែលបានអះអាងថា គាត់គឺជាអ្នករាយការណ៍ និងទទួលបញ្ជាពីថ្នាក់លើបំផុតនៃរបបនោះ រួមមានដូចជា ប៉ុល ពត[70] ឬ ពីគណៈភូមិភាគ[71]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចក្នុងសំណុំរឿង ០០២/០១ "ក្នុងការអនុវត្តជាក់ស្តែង កម្រិតនីមួយៗនៅក្នុងឋានានុក្រម [នៃបក្សកុម្មុយនីស្តកម្ពុជា] បានធ្វើការទំនាក់ទំនងគ្នាភាគច្រើនត្រឹមតែ

---

[67]ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4 ត្រង់ទំព័រ ៥-៧។ កិច្ចសម្ភាសន៍របស់ផលិតកម្ម Smiling Toad ជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, ឯកសារ D1.3.12.1 ត្រង់ទំព័រ ១៧។

[68] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៩។ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងធ្វើនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/19 ត្រង់ទំព័រ ២។

[69] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D119/65 ចម្លើយលេខ១២៨ ត្រង់ទំព័រ ២៣។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ ឆៅ ចាត់ នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/130 ចម្លើយលេខ១៩៨ ត្រង់ទំព័រ ២១។

[70] កិច្ចសម្ភាសន៍របស់ផលិតកម្ម Smiling Toad ជាមួយអ្នកស្រី អ៊ឹម ចែម នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, ឯកសារ D1.3.12.1 ត្រង់ទំព័រ ១៧។

[71] ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម នៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4 ត្រង់ទំព័រ ៧។

ជាមួយថ្នាក់លើ និងថ្នាក់ក្រោមផ្ទាល់របស់ខ្លួនតែប៉ុណ្ណោះ”[72]។ ជាពិសេស “ស្រុក និងឃុំ មិនមានទំនាក់ទំនងជាមួយនឹងគណៈកម្មាធិការមជ្ឈិមដោយផ្ទាល់ទេ”[73]។ ភស្តុតាងបន្ថែមលើភាពមិនអាចជឿជាក់បាននៃចម្លើយរបស់អ្នកស្រី អ៊ឹម ចែម ដែលបានផ្តល់ឲ្យ DC-Cam និងក្នុងពេលផ្តល់សម្ភាសន៍ជាមួយផលិតកម្ម Smiling Toad គឺជាការបញ្ជាក់អះអាងថា អ្នកស្រីមិនដែលធ្លាប់បានបង្កើតការដ្ឋានថ្មីណាមួយឡើយ ប៉ុន្តែអ្នកស្រីបានធ្វើការងារលើការដ្ឋានចាស់ដែលមានស្រាប់បន្តពីអ្នកគ្រប់គ្រងមុនៗ[74]។ ហេតុដូច្នេះ គ្មានភស្តុតាងណាដែលបញ្ជាក់អំពីអំណាចរបស់ អ្នកស្រី អ៊ឹម ចែម លើការដ្ឋានស្ពានស្រែង លើកលែងតែការបរិយាយអំពីហេតុការណ៍ដែលមិនអាចជឿជាក់បាន ដែលគ្រាន់តែជាចំណង់ ទោះជាចេតនា ឬ អចេតនាក្តី ក្នុងការពង្រីកឋានៈតាមរយៈការពន្លើសអំពីភាពសំខាន់របស់អ្នកស្រីនៅក្នុងព្រឹត្តិការណ៍នាពេលអតីតកាល។

៣៣. ខណៈដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មនៅការដ្ឋានស្ពានស្រែង “ក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ” នោះ មានភស្តុតាងបង្ហាញថា ការដ្ឋានស្ពានស្រែងការពិតស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ថ្នាក់តំបន់។ ចំណុចនេះ គឺសមហេតុផលស្របតាមរចនាសម្ព័ន្ធរបស់របបកម្ពុជាប្រជាធិបតេយ្យ មានសណ្ឋានជាខ្សែបណ្តោយ (ខ្សែរឈរ)[75] និងដោយហេតុថា ការដ្ឋានស្ពានស្រែងឆ្លងកាត់ពីរស្រុក គឺ ភ្នំស្រុក

---

[72] *សំណុំរឿងរបស់លោក នួន ជា និងជនជាប់ចោទដទៃទៀត* សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អ.វ.ត.ក/អ.ជ.ស.ជ, សាលក្រមនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ E313 ត្រង់កថាខណ្ឌ ២៧០។

[73] *សំណុំរឿងរបស់លោក នួន ជា និងជនជាប់ចោទដទៃទៀត* សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អ.វ.ត.ក/អ.ជ.ស.ជ, សាលក្រមនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ E313 ត្រង់កថាខណ្ឌ ២៧០។

[74] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ពុំ ខូ ធ្វើនៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ D219/23 ត្រង់ទំព័រ ២០។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឈិត យឿក ធ្វើនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ D67.9 ត្រង់ទំព័រ ៣៨។

[75] *សូមមើល* ដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ត្រង់កថាខណ្ឌ ៦៤-៦៨។

និង ព្រះនេត្រព្រះ[76]។

៣៤. អ្នកស្រី អ៊ឹម ចែម ត្រូវបានតែងតាំងជាលេខាស្រុកព្រះនេត្រព្រះចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧ និងបានរក្សាតួនាទីនេះ ពេញរយៈពេលដែលសេសសល់នៃរបបខ្មែរក្រហម។ ភស្តុតាងដែលត្រូវបានដាក់ក្នុងសំណុំរឿងបង្ហាញថា តួនាទីរបស់អ្នកស្រីជាលេខាស្រុក ត្រូវបានកំហិតត្រឹមការគ្រប់គ្រងតាមភូមិ និងឃុំនានាក្នុងស្រុកព្រះនេត្រព្រះតែប៉ុណ្ណោះ[77]។ ក្នុងតួនាទីនេះ អ្នកស្រីបានដឹកនាំអង្គប្រជុំមួយចំនួន ដោយលើកទឹកចិត្តឲ្យមានការបង្កបង្កើនផល ដើម្បីផលិតស្បៀងឲ្យបានគ្រប់គ្រាន់សម្រាប់ប្រជាជន ព្រមទាំងការកសាងទំនប់ និងប្រឡាយនៅក្នុងក្របខណ្ឌនៃស្រុកដែលអ្នកស្រីធ្វើជាប្រធាន[78]។ តាមរចនាសម្ព័ន្ធខ្សែបណ្តោយនៃរបបនេះ ឋានានុក្រមស្រុកព្រះនេត្រព្រះគឺស្ថិតក្រោមការគ្រប់គ្រងរបស់តំបន់៥[79] ហើយលេខាស្រុកទាំងឡាយគ្មានសិទ្ធិអំណាចគ្រប់គ្រងលើពហុស្រុក[80] ឬ មានអំណាចអ្វីនៅក្នុងថ្នាក់តំបន់ឡើយ។

---

[76] របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង ធ្វើនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/19 ត្រង់ទំព័រ ២។ *សូមមើលផងដែរ* ផែនទីនៃទីតាំងស្ពានស្រែង និងទំនប់ស្តុកទឹកព្រៃរនាមក្នុងតំបន់៥ នៃភូមិភាគពាយ័ព្យ នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/19.4។

[77] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ឈឹម ផន ធ្វើនៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣, ឯកសារ D119/32 ចម្លើយលេខ ៣៤។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី យ៉េង ផាន ធ្វើនៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤, ឯកសារ D119/132 ត្រង់ទំព័រ៦។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ពុំ ខូ នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ D219/23 ត្រង់ទំព័រ ៦។

[78] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ឈឹម ផន នៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣, ឯកសារ D119/32 ត្រង់ទំព័រ ៧។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ទុំ សឿន ធ្វើនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D119/65 ត្រង់ទំព័រ ១៤ និង ៣៨។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់អ្នកស្រី អ៊ឹម ម៉ន ធ្វើនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ D119/96 ត្រង់ទំព័រ ១៨។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី កោ ឡិន នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/98 ត្រង់ទំព័រ ១០។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ពុំ ខូ នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ D219/23 ត្រង់ទំព័រ ៦។

[79] *សូមមើល* ដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ត្រង់កថាខណ្ឌ ៦៤ និង ៦៨។

[80] *សូមមើល* សាលក្រម*ឌុច* ត្រង់កថាខណ្ឌ ៩០។

៣៥. ចំណុចជាក់លាក់ទាក់ទងនឹងការដ្ឋានស្ពានស្រែង គឺមានភស្តុតាងបង្ហាញថា ការដ្ឋាននេះពិតជាស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់តំបន់[81]។ កម្មករទាំងឡាយត្រូវបានគ្រប់គ្រងដោយប្រធានកងចល័តមកពីថ្នាក់តំបន់[82]។ នេះគឺជាការពិតមុនពេល[83] និងបន្ទាប់ពី[84] *តា ក៉ែវ* ជាប្រធានកងចល័តតំបន់៥ត្រូវបានចាប់ខ្លួននាពាក់កណ្តាលឆ្នាំ១៩៧៧[85]។ តួនាទីតែមួយគត់របស់អ្នកស្រី អ៊ឹម ចែម ក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះដែលពាក់ព័ន្ធទៅនឹងការងារនៅការដ្ឋាន គឺការផ្តល់កម្លាំងតាមសំណើ

[81] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ជុំ កាន់ ធ្វើនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/110 ត្រង់ទំព័រ ១៥។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ពុំ ខូ ធ្វើនៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ D219/23 ត្រង់ទំព័រ ២០។

[82] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ជាម គិន ធ្វើនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ D119/100 ត្រង់ទំព័រ ៦។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី កោ ឡិន ធ្វើនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/98 ត្រង់ទំព័រ ១០។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ជុំ កាន់ នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/110 ត្រង់ទំព័រ ១៥។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ពុំ ខូ នៅថ្ងៃទី ៦ តុលា ឆ្នាំ ២០១៤, ឯកសារ D219/23 ត្រង់ទំព័រ ២០។

[83] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ពុំ ខូ នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ D219/23 ត្រង់ទំព័រ ៧។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី មុត មុន នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤, ឯកសារ D119/139 ត្រង់ទំព័រ ១៧។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី តក់ ប៊ុយ នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/9 ត្រង់ទំព័រ ២។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ឆាយ ផាន នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៣ ត្រង់ទំព័រ ៤។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ជាម គិន នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ D119/100 ត្រង់ទំព័រ ៦។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ជុំ ជិម នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥, ឯកសារ D219/149 ត្រង់ទំព័រ ៥។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី សម ស័ក្ក នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D119/120 ត្រង់ទំព័រ ១២។

[84] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី នៅ ចាត់ នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/130 ត្រង់ទំព័រ ៣១។

[85] *សូមមើល* បញ្ជីឈ្មោះអ្នកទោសដែលត្រូវសម្លាប់របស់មន្ទីរស២១, ការសម្លាប់អ្នកទោសចំនួន ៣៩ នាក់ដែលមិនបានចុះបញ្ជីចុះនៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៧៨, ឯកសារ D6.1.1128, ភាសាអង់គ្លេស ERN 00193556។

របស់ថ្នាក់តំបន់[86]។ តួយ៉ាង សាក្សី ជុំ កាន់ ជាអតីតគណៈឃុំភ្នំលៀប បានរំលឹកអំពីការប្រជុំមួយប្រព្រឹត្តទៅនៅការិយាល័យស្រុកព្រះនេត្រព្រះ ដែលក្នុងពេលនោះកម្មាភិបាលតំបន់៥បានស្នើសុំកម្លាំងប្រជាជនពីថ្នាក់មូលដ្ឋានដើម្បីដាក់តាមការដ្ឋានមួយចំនួន[87]។ បើទោះជាអ្នកស្រី អ៊ឹម ចែម មានវត្តមាននៅក្នុងអង្គប្រជុំនោះក៏ដោយ ក៏អ្នកស្រីមិនបាននិយាយអ្វីឡើយ[88]។ ចំណុចនេះមិនត្រឹមតែចង្អុលបង្ហាញថា ការដ្ឋានទាំងនោះស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់តំបន់តែប៉ុណ្ណោះទេ គឺវាថែមទាំងចង់បង្ហាញថា អ្នកស្រី អ៊ឹម ចែម មិនបានអនុវត្តតួនាទីអ្វីជាដុំកំភួនណាមួយទាក់ទងនឹងការដ្ឋានអស់នោះ មិនថា ជាអំណាច*ជាក់ស្តែង* ឬ ជាអំណាច*ផ្លូវច្បាប់*ឡើយ បើមិនដូច្នោះទេនោះម៉្លេះសមនឹងអ្នកស្រីចូលរួមពិភាក្សាអំពីបញ្ហានេះទៅកាន់អ្នកចូលរួមអង្គប្រជុំនោះមិនខានឡើយ។

## *ខ.៣. មន្ទីរសន្តិសុខភ្នំទ្រយោង*

៣៦. នៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី សហព្រះរាជអាជ្ញាអន្តរជាតិបានចោទប្រកាន់ដូច្នេះថា៖

> មន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានវាយយកថ្មដែលជាប់ពាក់ព័ន្ធមួយកន្លែង មានទីតាំងនៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ (ដែលជាផ្នែកមួយរបស់តំបន់៥នៃភូមិភាគពាយ័ព្យ)។ តាមការប៉ាន់ស្មាន មានប្រជាជនរហូតដល់ទៅ ៤០.០០០ នាក់ បានស្លាប់នៅក្នុងទីតាំងនេះចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៩។ មន្ទីរសន្តិសុខភ្នំទ្រយោង ជាគុកថ្នាក់តំបន់សម្រាប់តំបន់៥ និងជាមន្ទីរសន្តិសុខដ៏ធំជាងគេបំផុតនៅក្នុងតំបន់នេះ។ មនុស្សមកពីតំបន់៥ទាំងមូល និងសូម្បីតែអ្នកទោសមកពីតំបន់៣ ក៏ត្រូវបានឃុំខ្លួននៅទីនេះដែរ។

[86] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ជុំ កាន់ នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/110 ត្រង់ទំព័រ ១៦។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ពុំ ខូ នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ D219/23 ត្រង់ទំព័រ ៧។

[87] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ជុំ កាន់ នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/110 ត្រង់ទំព័រ ១៣-១៤។

[88] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ជុំ កាន់ នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/110 ត្រង់ទំព័រ ១៣-១៤។

មន្ទីរសន្តិសុខភ្នំទ្រយោង មានតួនាទីជាកន្លែងអប់រំលត់ដំដល់សមាសភាពក្បត់តាមការចោទប្រកាន់ ជាការដ្ឋានធ្វើការដោយបង្ខំ និងជាទីតាំងសម្លាប់មនុស្សដែលត្រូវបានយល់ថា ជាខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ។ អ្នកជាប់ឃុំឃាំងទាំងនេះដែលត្រូវចាត់ថ្នាក់ថា ជាអ្នកប្រព្រឹត្តល្មើសធ្ងន់ធ្ងរ ត្រូវបង្ខំឱ្យធ្វើការនៅក្នុងការដ្ឋានបំបែកថ្ម និងត្រូវផ្តល់របបអាហារតែបបរមួយវែកប៉ុណ្ណោះក្នុងមួយពេល។ អ្នកដែលមិនធ្វើការឱ្យបានស្វាហាប់នោះទេ ត្រូវសម្លាប់ចោលហើយអ្នកខ្លះបានស្លាប់ដោយសារការអត់ឃ្លាន ឬធ្វើការហួសកម្លាំង។ ឈ្លបឃុំ និងកម្មាភិបាលភូមិភាគនិរតីនៅក្រោមការគ្រប់គ្រងរបស់ [អ្នកស្រី] អ៊ឹម ចែម [ជាអ្នក] ទទួលខុសត្រូវចំពោះការចាប់ខ្លួនប្រជាជន និងនាំប្រជាជនទៅសម្លាប់នៅភ្នំទ្រយោង។ ការសម្លាប់ដែលមានច្រើនរហូតដល់ទៅ ១៥នាក់ក្នុងមួយយប់ៗ ត្រូវបានធ្វើឡើងនៅផ្នែកខាងជើងភ្នំទ្រយោង[89]។

៣៧. នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ចៅក្រម HARMON បានធ្វើការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ក្នុងមុខតំណែងជាលេខាស្រុកព្រះនេត្រព្រះ លើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ នៅមន្ទីរសន្តិសុខភ្នំទ្រយោងពីចន្លោះខែ មេសា ឆ្នាំ ១៩៧៧ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ អ្នកស្រី អ៊ឹម ចែម ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋទាំងនេះ តាមរយៈការប្រព្រឹត្ត ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងជំរុញ និងតាមរយៈការទទួលខុសត្រូវថ្នាក់លើ[90]។

## ស្ថានទម្ងន់នៃបទឧក្រិដ្ឋ

៣៨. ស្ថានទម្ងន់នៃបទឧក្រិដ្ឋ ដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានទទួលរងការចោទប្រកាន់នៅឯភ្នំទ្រយោង អាចនឹងត្រូវបានកំណត់ដោយផ្អែកលើកត្តាមួយចំនួន រួមមានដូចជា ចំនួនជនរងគ្រោះ វិសាលភាពភូមិសាស្ត្រ និងពេលវេលា និងលក្ខណៈនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ព្រម

---

[89] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៤-៧៥ (ឯកសារយោងត្រូវបានលុប)។

[90] *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D239.1។

ទាំងព្រឹត្តិការណ៍ដាច់ដោយឡែកមួយចំនួនទៀត[91]។ ការវិភាគភស្តុតាងទាក់ទងនឹងភ្នំទ្រយោង បង្ហាញឲ្យឃើញថា ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងអម្បាលម៉ានមិនបានបំពេញនូវលក្ខខណ្ឌ ស្ថានទម្ងន់ដែលតម្រូវដោយប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឡើយ។

៣៩. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា "មានប្រជាជនរហូតដល់ទៅ ៤០.០០០ នាក់បានស្លាប់ នៅ [ភ្នំទ្រយោង] ក្នុងចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៩"[92]។ ការចោទប្រកាន់នេះ បានផ្អែកលើ របាយការណ៍របស់ DC-Cam កាលពីឆ្នាំ១៩៩៧។ របាយការណ៍នេះ ផ្តល់នូវតួលេខជនរងគ្រោះ ចំនួន៤ម៉ឺននាក់ ដោយគ្មានឯកសារយោងអ្វីទាំងអស់។ តាមការពិតទៅ របាយការណ៍បានគូស បញ្ជាក់យ៉ាងច្បាស់ថា ក្រុមការងារកំណត់ទីតាំងភូមិសាស្ត្រវាលពិឃាតក្នុងប្រទេសកម្ពុជាមិនបាន ធ្វើដំណើរទៅដល់ភ្នំទ្រយោងឡើយ ហើយថាពួកគេ "មិនអាចរង់ចាំរហូតដល់ពេលរកឃើញសាក្សី ឬ បន្តការស្រាវជ្រាវ [របស់ខ្លួន]" ពីទីតាំងមួយនេះទេ[93]។ ដោយហេតុថា សហព្រះរាជអាជ្ញា អន្តរជាតិសំអាងលើរបាយការណ៍របស់ DC-Cam ធ្វើនៅឆ្នាំ១៩៩៧ ដើម្បីដាក់ដីកាសន្និដ្ឋានបញ្ជូន រឿងឲ្យស៊ើបសួរលើកទីបី ដែលមានរយៈពេលប្រមាណជាដប់ឆ្នាំក្រោយពីចេញរបាយការណ៍នេះ DC-Cam មិនដែលបានផ្តល់នូវបច្ចុប្បន្នភាពនៃតួលេខដែលលើកឡើងពីដំបូង ឬ សូម្បីតែផ្តល់នូវ ប្រភពឯកសារយោងដែលគាំទ្រតួលេខខាងលើនេះឡើយ។ ហេតុដូចនេះ គ្មានមូលដ្ឋានត្រឹមត្រូវអ្វី ដើម្បីអះអាងថា មានជនរងគ្រោះចំនួនរហូតដល់ទៅ៤ម៉ឺននាក់បានស្លាប់នៅភ្នំទ្រយោងនោះទេ។ លើសពីនេះទៀត ដោយយោងទៅលើកិច្ចសម្ភាសន៍របស់ DC-Cam ជាមួយសាក្សី តក់ ប៊ុយ

---

[91] សាលក្រម*ឌុច* ត្រង់កថាខណ្ឌ ២២។

[92] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ៧៤ *យោង* របាយការណ៍របស់ក្រុមការងារកំណត់ទីតាំងភូមិសាស្ត្រវាលពិឃាតក្នុងប្រទេសកម្ពុជានៅកម្ពុជាឆ្នាំ១៩៩៧៖ ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧, ឯកសារ D1.3.10.10, ភាសាអង់គ្លេស ERN 00218610។

[93] ការកំណត់ទីតាំងវាលពិឃាតនៅកម្ពុជាឆ្នាំ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧, ឯកសារ D1.3.10.10 ភាសាអង់គ្លេស ERN 00218610។ *សូមមើលផងដែរ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ស៊ិន ឃិន នៅថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D219/206 ត្រង់ទំព័រ ៥ (ដែលបានបញ្ជាក់អះអាងថាក្រុមធ្វើផែនទីរបស់ DC-Cam មិនបានទៅដល់ភ្នំទ្រយោងក្នុងអំឡុងបេសកកម្មកាលពីឆ្នាំ ១៩៩៧ ឡើយ)។

សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ក្នុងមួយយប់ មានមនុស្សចំនួនរហូតដល់១៥នាក់ ត្រូវបានគេសម្លាប់នៅភ្នំទ្រយោង[94]។ ការចោទប្រកាន់ទាំងនេះ មិនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដូចដែលត្រូវបានចោទប្រកាន់នៅភ្នំទ្រយោងឡើយ ប៉ុន្តែវាទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានកើតឡើងនៅទំនប់ទឹកត្រពាំងថ្មូងណោះទេ[95]។ ហេតុនេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីគ្មានភស្តុតាងជាមូលដ្ឋានអ្វីទាល់តែសោះ ដើម្បីចោទប្រកាន់បានថា មានការសម្លាប់នៅភ្នំទ្រយោង ហើយថាមានជនរងគ្រោះដែលបានស្លាប់នៅទីនោះបានកើនឡើងរហូតដល់ចំនួន៤ម៉ឺននាក់។

៤០. មិនមានអ្វីដែលមានតម្លៃជាភស្តុតាងឡើយនៅក្នុងសំណុំរឿងនេះ ដើម្បីអាចគាំទ្រដល់ការចោទប្រកាន់ដែលថា មានការសម្លាប់បានកើតឡើងនៅក្នុងកម្រិតនៃការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។ សាក្សីមួយចំនួនដែលត្រូវបានកោះហៅមកសាកសួរអំពីតួលេខអ្នកស្លាប់ចំនួន៤ម៉ឺននាក់នេះ បានធ្វើការប៉ាន់ប្រមាណក្នុងចំនួនតិចជាងនេះឆ្ងាយ[96] ឬ បានទាំងចោទសួរអំពីបែបបទនៃការប្រមូលតួលេខនេះទៅវិញ[97]។ លើសពីនេះ សាក្សី ឡាយ ខាន់ ជាសាក្សីតែម្នាក់គត់ដែលត្រូវបានបង្ហាញថា ជាអ្នកបានបញ្ជាក់អះអាងអំពីចំនួនអ្នកស្លាប់ក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់គាត់ ប៉ុន្តែតាមការពិត សាក្សីរូបនេះ មិនដែលបានថ្លែងដូច្នេះឡើយក្នុងបទសម្ភាសន៍របស់ខ្លួន។ ជាក់ស្តែង ចម្លើយជាភស្តុតាងរបស់ ឡាយ ខាន់ ត្រូវបានកត់

---

[94] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ត្រង់ចំណុច ៧៥ *យោង* កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ តក់ ប៊ុយ កាលពីថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.11.52 ត្រង់ទំព័រ ១០។

[95] *សូមមើល* កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ តក់ ប៊ុយ នៅថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.11.52 ត្រង់ទំព័រ ៩-១០។

[96] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ធិប សំផាត់ នៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/8 ត្រង់ទំព័រ ៧។

[97] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ស៊ិន ឃិន នៅថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D219/206 ត្រង់ទំព័រ ៦ ("[អ្នកដើរអមដំណើរជាមួយខ្ញុំ] បាននិយាយថាគាត់ឮពីប្រជាជននិយាយប្រាប់ [តួលេខ] នេះ... [មជ្ឈមណ្ឌលឯកសារកម្ពុជាបានចំនួននេះមកពីណា] ខ្ញុំមិនដឹង ខ្ញុំមិនបានទៅដល់ទីនោះទេ [ភ្នំទ្រយោង]។ ហើយក៏មិនមានសាក្សីផ្ទាល់ពីកន្លែងនោះដែលអាចនិយាយប្រាប់ខ្ញុំអំពីរឿងនេះបានដែរ...ពេលខ្ញុំស្តាប់កាសែត ខ្ញុំមិនបានឮគេនិយាយអំពីភ្នំទ្រយោងទេ") ត្រង់ចម្លើយ៣៨-៤២ ។

ចូលខុសទៅក្នុងកំណត់ហេតុស្តាប់ ចម្លើយជាលាយលក្ខណ៍អក្សរ ដែលធ្វើឲ្យមានទម្ងន់ដាក់បន្ទុកលើសការពិត [98]។ ដោយគ្មានការធ្វើកោសល្យវិច័យលើភស្តុតាងដូច្នេះ តម្លៃជាភស្តុតាងតែមួយគត់ត្រូវតែបានមកពីសាក្សីដែលបានឃើញដោយផ្ទាល់ភ្នែកនូវចំនួនមនុស្សស្លាប់ ដែលត្រូវបានចោទប្រកាន់នៅភ្នំទ្រយោង។

៤១. ទាក់ទងនឹងការចោទប្រកាន់ថាមានការសម្លាប់វិញ មានភស្តុតាងដែលបានពីសាក្សីផ្ទាល់ភ្នែកបង្ហាញឲ្យឃើញនូវភាពខុសគ្នាឆ្ងាយពីការកើតឡើងជាទៀងទាត់ ពោលគឺកម្រមាននូវការសម្លាប់ ហើយព្រឹត្តិការណ៍នេះ បានកើតឡើងដាច់ដោយឡែកមុនពេលកងទ័ពវៀតណាមបានមកដល់។ មានតែសាក្សី ធិប សំផាត់ ប៉ុណ្ណោះ ដែលបានអះអាងថា មានការសម្លាប់បានកើតឡើងជារៀងរាល់យប់[99] ហើយក្រោយមកទៀត សាក្សីរូបនេះ បានត្រឹមតែទទួលស្គាល់ថា គាត់បានឃើញការសម្លាប់តែម្តងគត់[100]។ ស្រដៀងគ្នានេះដែរ សាក្សី គឹម យ៉េត ដែលកាលពីដំបូងបាននិយាយថា ការសម្លាប់បានកើតឡើងជារៀងរាល់សប្តាហ៍[101] តែក្រោយមក គាត់បានបដិសេធចម្លើយរបស់គាត់វិញ[102] និងបានទទួលស្គាល់ថា គាត់មិនដែលបានឃើញការសម្លាប់ដោយផ្ទាល់ភ្នែកនោះទេ[103]

---

[98] *ប្រៀបធៀប* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ឡាយ ខាន់ នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/4 ត្រង់ទំព័រ ៤ ("ខ្ញុំអាចប៉ាន់ស្មានថា <u>មានមនុស្សជាច្រើនបានស្លាប់នៅទីនោះ</u> ហើយចំនួននេះ [៤ម៉ឺននាក់] ប្រហែលជាត្រឹមត្រូវហើយអាចជាការត្រឹមត្រូវ" (សេចក្តីបញ្ជាក់បន្ថែម) និងប្រតិចារឹកនៃការស្តាប់ចម្លើយរបស់សាក្សី ឡាយ ខាន់ នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D219/422.2 ត្រង់ទំព័រ ១១ ("បាទ តាមដែលខ្ញុំយល់ <u>ប្រហែលជាបានគ្រប់៤០.០០០ នាក់</u>។ ច្រើនណាស់ បាទ" (គូសបញ្ជាក់បន្ថែម)។

[99] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ធិប សំផាត់ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/49 ត្រង់ទំព័រ ១១។ ថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ១៧-១៨។

[100] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ធិប សំផាត់ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/49 ត្រង់ទំព័រ ១១-១២។

[101] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី គិម យ៉េត ធ្វើនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/6 ត្រង់ទំព័រ ៧។

[102] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ គិម យ៉េត, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/94, ទំព័រ ១៣។

ហើយក៏មិនបានឮដែរថា បុគ្គលឈ្មោះ ទុំ សឿន ដែលត្រូវបានចោទប្រកាន់ថាមានតួនាទីជាប្រធានគុកភ្នំទ្រយោង គឺជាអ្នកដែលបានបញ្ជាឱ្យសម្លាប់អ្នកទោសឡើយ[104]។ សាក្សីមួយចំនួនផ្សេងទៀតបានផ្តល់ភស្តុតាងតិចតួចបំផុតនៅពេលមានការសួរនាំអំពីភាពញឹកញាប់នៃការសម្លាប់មនុស្សដែលរងការចោទប្រកាន់។ តាមការពិត បើទោះបីជាមានចំណុចមិនស៊ីសង្វាក់គ្នាសំខាន់ៗក្នុងចម្លើយរបស់សាក្សីមួយចំនួនក្តី[105] ក៏តួលេខខ្ពស់បំផុតដែលត្រូវបានផ្តល់ទាក់ទងនឹងការសម្លាប់មនុស្សនៅភ្នំទ្រយោង គឺមានជនរងគ្រោះចំនួន៨០នាក់ប៉ុណ្ណោះ ដោយក្រុមទាហាន នៅពេលដែលកងទ័ពវៀតណាមបានកំពុងខិតជិតចូលដល់[106]។

---

[103] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ គិម យ៉េត ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/94 ត្រង់ទំព័រ ១១។

[104] កំណត់ហេតុនៃការតទល់មុខគ្នា ចុះថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ៤២។

[105] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ធិប សំផាត់ ធ្វើនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ D119/49 ត្រង់ទំព័រ ១១-១២ (ដែលបាននិយាយថានៅពេលវៀតណាមចូល គាត់បានឃើញទាហានសម្លាប់អ្នកទោសធូន់ចំនួន ៨០ នាក់ "នៅពេលនោះគឺវៀតណាមជិតចូលមកដល់ ដូច្នេះហើយត្រូវបញ្ចេញអ្នកទោសទាំងអស់ចេញ")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ផុន ម៉ុន ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/95 ត្រង់ទំព័រ ៩ (ដែលបាននិយាយថាមានពេលមួយនោះ គាត់ត្រូវបានស្នើឱ្យកប់សាកសពចំនួន៧នាក់ "ឈ្មោះទី ហើយនិងខ្ញុំត្រូវបានគេហៅឱ្យទៅកប់សាកសពអ្នកទោស៧នាក់")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ គិម យ៉េត ធ្វើនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/94 ត្រង់ទំព័រ ១២ (ដែលបាននិយាយថាមានម្តងនោះ គាត់ត្រូវបានស្នើឱ្យកប់សាកសពមនុស្សចំនួន៣០ទៅ៤០នាក់ "ប្រហែលពី៣០ ទៅ៤០នាក់")។ កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ២៩ (សាក្សី ទុំ សឿន បាននិយាយថាមានអ្នកទោសធូន់ចំនួន៤នាក់ប៉ុណ្ណោះដែលត្រូវបានសម្លាប់នៅភ្នំទ្រយោង)។

[106] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ធិប សំផាត់ ធ្វើនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ D119/49 ត្រង់ទំព័រ១១-១២ (ដែលបាននិយាយថានៅពេលកងទ័ពវៀតណាមចូល គាត់បានឃើញទាហានសម្លាប់អ្នកទោសធូន់ចំនួន៨០នាក់)។ ដើម្បីឱ្យប្រាកដ ក្រុមការពារក្តីសូមធ្វើការកត់សម្គាល់ថា សាក្សី ទុំ សឿន មិនដែលបានទទួលស្គាល់ថា "មានប្រជាជនចំនួនប្រមាណ ៣០០ ឬ ៤០០ នាក់បានស្លាប់" នៅភ្នំទ្រយោងឡើយ ដូចដែលបានកត់សម្គាល់ក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់គាត់។ ផ្ទុយទៅវិញ គាត់បាននិយាយថានេះជាចំនួនប្រជាជនដែលបានរស់នៅទីនោះ។ *ប្រៀបធៀប* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ទុំ សឿន ធ្វើនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/5 ត្រង់ទំព័រ ៥ និង ប្រតិចារឹកនៃការស្តាប់ចម្លើយរបស់ ទុំ សឿន ធ្វើនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D219/422.9 ត្រង់ទំព័រ ១៦ និង ២៦។

៤២. ក្រៅពីព្រឹត្តិការណ៍ជាក់លាក់មួយនេះ ការសម្លាប់ហាក់បានប្រព្រឹត្តទៅម្តងម្កាល និងជាព្រឹត្តិការណ៍ដាច់ដោយឡែកពីគ្នា។ ដូច្នេះ ចំនួនមនុស្សស្លាប់សរុប មិនអាចច្រើនលើសពី៩០នាក់ឡើយ ដែលតាមការចោទទាក់ទងថាមានការសម្លាប់នេះ គឺធ្វើឡើងចំពោះអ្នកមានទោសកំហុសធ្ងន់ធ្ងរ នៅមុនពេលវៀតណាមចូលលុកលុយ។ ភាពខុសគ្នារវាងការសម្លាប់មនុស្សចំនួន ៩០ នាក់ដែលផ្អែកលើភស្តុតាងមានក្នុងដៃ និងការសម្លាប់មនុស្សចំនួន៤ម៉ឺននាក់ដែលគ្មានភស្តុតាងសំអាង គឺមានទំហំខុសគ្នាឆ្ងាយខ្លាំងណាស់ រហូតវាបានបង្កើតជាចម្ងល់មួយ ថាតើសហព្រះរាជអាជ្ញាអន្តរជាតិ អាចអះអាងប្រកបដោយការទទួលខុសត្រូវយ៉ាងដូចម្តេច ចំពោះតួលេខបំផ្លើសដ៏គួរឲ្យអស់សំណើចនៅចំពោះវត្តមានភស្តុតាងដែលមានទាំងនេះ។ ជាការពិតណាស់ដែលការសម្លាប់ជីវិតមនុស្សចំនួន៩០នាក់ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយក្នុងបរិបទនៃ "វាលពិឃាត" នៅកម្ពុជា ប៉ុន្តែវាមិនមែនជាអំពើឃោរឃៅដ៏គួរឲ្យកត់សម្គាល់ឡើយ (មានន័យថា វាបានកើតឡើងជាទូទៅនៅក្នុងសម័យកាលនោះ)។ បើគិតជាចំនួនវិញ ការស្លាប់មនុស្សចំនួន៩០នាក់នេះ គឺតិចជាង ១/១៣៥ (មួយលើមួយរយសាមសិបប្រាំ) នៃចំនួនមនុស្សដែលត្រូវបានសម្លាប់នៅឯមន្ទីរស២១ ដែលនៅទីនោះ មានមនុស្សចំនួន ១២.២៧២ នាក់ (មួយម៉ឺនពីរពាន់ពីររយចិតសិបពីរនាក់) បានទទួលរងទារុណកម្ម និងត្រូវបានសម្លាប់[107] ហើយតួលេខនេះ វាស្មើនឹង ១/៤៤៤ (មួយលើបួនរយសែសិបបួន) នៃតួលេខមនុស្សចំនួន៤ម៉ឺននាក់ដែលត្រូវចោទថាបានសម្លាប់នៅភ្នំទ្រយោង។ តួលេខនេះ ក៏តិចជាងទីតាំងឧក្រិដ្ឋកម្មខ្លះក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មមួយចំនួនទៀត ដែលត្រូវបានយកមកពិនិត្យផ្ទៀងផ្ទាត់សម្រាប់ប្រើប្រាស់ក្នុងសវនាការនៃសំណុំរឿង០០២ផងដែរ[108]។ ទោះយ៉ាងណាក្តី ចំនួនជនរងគ្រោះនេះ មិនអាចលើសចំនួនប្រជាជនសរុបដែលបានរស់នៅជុំវិញភ្នំទ្រយោងឡើយ។ បើតាមការប៉ាន់ប្រមាណ មានប្រជាជនចំនួនចន្លោះពី ២០០ នាក់ (ពីររយ) ដល់ ៥០០ នាក់

[107] *សូមមើល* សាលដីកាលើសំណុំរឿងរបស់ *ឌុច* ត្រង់កថាខណ្ឌ ២។

[108] *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ត្រង់កថាខណ្ឌ ៥០០ (ដែលបានប៉ាន់ប្រមាណថាអ្នកជាប់ឃុំឃាំងប្រមាណមួយម៉ឺនប្រាំពាន់នាក់ ត្រូវបានសម្លាប់នៅក្រាំងតាចាន់) កថាខណ្ឌ ៧៨៣ (ដែលប៉ាន់ប្រមាណថាមនុស្សចំនួនបីម៉ឺននាក់ ត្រូវបានសម្លាប់នៅវត្តអូរត្រកួន)។

(ប្រាំរយ)[109] បានរស់នៅទីនោះ។

៤៣. ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាបានប្រព្រឹត្តទៅនៅភ្នំទ្រយោង សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ទីតាំងនេះ ត្រូវបានប្រើប្រាស់ជាការដ្ឋានសម្រាប់ឲ្យអ្នកទោសធ្វើការដោយបង្ខំ[110] ហើយចំពោះ "អ្នកដែលមិនធ្វើការឲ្យបានស្វាហាប់នោះទេត្រូវសម្លាប់ចោល" [111] និងដែល "អ្នកខ្លះត្រូវបានស្លាប់ដោយសារការអត់ឃ្លាន និងធ្វើការហួសកម្លាំង" [112]។ ការចោទប្រកាន់ទាំងនេះ គ្មានការគាំទ្រពីភស្តុតាងដែលប្រមូលបានក្នុងអំឡុងនៃកិច្ចស៊ើបអង្កេតឡើយ ។

៤៤. អំណះអំណាងដែលថា រាល់អ្នកដែលមិនធ្វើការឲ្យបានស្វាហាប់នឹងត្រូវបានសម្លាប់ គឺផ្អែកលើការសន្និតរបស់សាក្សីម្នាក់ ឈ្មោះ ឡាយ ខាន់ ។ សាក្សីរូបនេះ បានរស់នៅក្បែរការដ្ឋាន ប៉ុន្តែគាត់មិនអាចចូលទៅដល់ទីតាំងនោះបានទេ[113] ហើយម្យ៉ាងវាជាភស្តុតាងពាក្យចចាមអារាម។ ការពិតទៅ ក្រោយមកទៀត សាក្សី ឡាយ ខាន់ បានទទួលស្គាល់ថាគាត់ "បានដឹង [អំពីការចាប់ខ្លួន

---

[109] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី គិម យ៉េត ធ្វើនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/6 ត្រង់ទំព័រ ៧។ ប្រតិចារឹកនៃការស្តាប់ចម្លើយរបស់ ទុំ សឿន ធ្វើនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D219/422.9 ត្រង់ទំព័រ ១៦, ២៦ និងទំព័រ២៩ ។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D119/30 ត្រង់ទំព័រ ៦។

[110] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី, កថាខណ្ឌ ៧៥, *យោង* ការស្តាប់ចម្លើយរបស់ រិន ខេង ពីសំណាក់ ក.ស.ព, ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០៨, ឯកសារ D1.3.11.43 ត្រង់ទំព័រ ៣។

[111] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៥ *យោង* ការស្តាប់ចម្លើយរបស់ ឡាយ ខាន់ ពីសំណាក់ ក.ស.ព ធ្វើនៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៥, ឯកសារ D1.3.11.27 ត្រង់ទំព័រ ៣។

[112] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៥ *យោង* ការស្តាប់ចម្លើយរបស់ យក់ នាម ធ្វើនៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៨, ឯកសារ D1.3.11.69 ត្រង់ទំព័រ ៤។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4 ត្រង់ទំព័រ ៨-១០។

[113] *សូមមើល* ការស្តាប់ចម្លើយរបស់ ឡាយ ខាន់ ពីសំណាក់ ក.ស.ព ធ្វើនៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៥, ឯកសារ D1.3.11.27 ត្រង់ទំព័រ ៣។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ឡាយ ខាន់ ធ្វើនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/4 ត្រង់ទំព័រ ៤។

និងការសម្លាប់] ព្រោះ[គាត់]បានសួរអ្នកនៅក្បែរៗ[គាត់]”[114]។

៤៥. បន្ថែមពីលើនេះ មានបទសម្ភាសន៍ចំនួនពីរដែលសហព្រះរាជអាជ្ញាបានលើកយកមកធ្វើជាសំអាង ដើម្បីជាការគាំទ្រលើអំណះអំណាងដែលថា មានប្រជាជនខ្លះនៅភ្នំទ្រយោងបានស្លាប់ដោយការអត់ឃ្លាន និងធ្វើការហួសកម្លាំង គឺមិនពាក់ព័ន្ធសូម្បីតែបន្តិចទៅនឹងទីតាំងឧក្រិដ្ឋកម្មនេះ ។ ប្រភពទីមួយដែលជាបទសម្ភាសន៍របស់សាក្សី យក់ នាម បានបញ្ជាក់យ៉ាងច្បាស់ថា សាក្សីពុំបានដឹងថាស្ថានភាពនៅភ្នំទ្រយោងមានលក្ខណៈដូចម្តេចឡើយ[115]។ ក្រោយមកសាក្សី យក់ នាម បានបញ្ជាក់បំភ្លឺថាគាត់បានដឹងអំពីភ្នំទ្រយោង ក្រោយពេលរបបខ្មែរក្រហមដួលរលំ[116]។ ហេតុនេះ ភស្តុតាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គ្មានភាពអាចជឿជាក់បាននោះទេ។ ប្រភពទីពីរដែលជាកិច្ចសម្ភាសន៍របស់ DC-Cam ជាមួយអ្នកស្រី អ៊ឹម ចែម គ្រាន់តែជាការពិពណ៌នារបស់អ្នកស្រី អ៊ឹម ចែម អំពីសភាពការណ៍ក្នុងស្រុកព្រះនេត្រព្រះទាំងមូលនៅពេលអ្នកស្រីមកដល់ប៉ុណ្ណោះ[117]។ បើទោះបីជាមានសាក្សីខ្លះបាននិយាយថា មានប្រជាជនខ្លះនៅភ្នំទ្រយោងបានស្លាប់ដោយការធ្វើការហួសកម្លាំង មានការអត់ឃ្លាន ឬ មានជំងឺក៏ដោយ[118] ក៏ការថ្លែងទាំងនេះ គ្មានភាពអាចជឿជាក់បានសម្រាប់បង្ហាញឲ្យឃើញថា នេះគឺជាផ្នែកមួយនៃគោលនយោបាយឡើយ ប៉ុន្តែជា

---

[114]កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ឡាយ ខាន់ ធ្វើនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/4 ត្រង់ទំព័រ ៤។

[115] ការស្តាប់ចម្លើយរបស់សាក្សី យក់ នាម ពីសំណាក់ ក.ស.ព ធ្វើនៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៨, ឯកសារ D1.3.11.69 ត្រង់ទំព័រ ៣។

[116] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី យក់ នាម ធ្វើនៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥, ឯកសារ D219/140 ត្រង់ទំព័រ ២០។

[117] ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4 ត្រង់ទំព័រ ៨-១០។

[118] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ស៊ុម សល់ ធ្វើនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/7 ត្រង់ទំព័រ ៥។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/92 ត្រង់ទំព័រ ១២។

លទ្ធផលនៃទុក្ខលំបាកដែលបានកើតឡើងអស់ពេលជាងពីរឆ្នាំនៅក្នុងស្រុកព្រះនេត្រព្រះ[119]។ ជាក់ស្តែង គ្មានភស្តុតាងណាដែលបង្ហាញថាអ្នកស្រី អ៊ឹម ចែម បានផ្តួចផ្តើម ឬបានអនុវត្តគោលនយោបាយនៃការសម្លាប់ប្រជាជនតាមរយៈការធ្វើការងារហួសកម្លាំង ការបង្កឱ្យមានភាពអត់ឃ្លាន ឬ មានជំងឺឡើយ។

៤៦. មានភស្តុតាងខ្លះៗដើម្បីបង្ហាញថា តាមការពិត ភ្នំទ្រយោងគឺជាអតីតមន្ទីរសន្តិសុខមួយដែលត្រូវបានបង្កើតឡើងនៅរវាងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៦[120] ហើយបានបញ្ចប់លែងមានអត្ថិភាពនៅពេលអ្នកស្រី អ៊ឹម ចែម បានមកដល់ក្នុងស្រុកព្រះនេត្រព្រះ[121]។ ចាប់ពីឆ្នាំ ១៩៧៧ ភ្នំទ្រយោងត្រូវបានបង្កើតឡើងក្នុងនាមជាសហករណ៍គំរូ[122] ដែលរាល់ការអនុវត្តក្នុងសហករណ៍ គឺមិនខុសពីអ្វីដែលបានកើតឡើងនៅតាមសហករណ៍ដទៃទៀតនៅទូទាំងប្រទេសឡើយ ។ នៅពេលដែលភ្នំទ្រយោងត្រូវបានពិពណ៌នាថាជា "គុកឥតជញ្ជាំង"[123] អ្នកមានទោសកម្រិតស្រាលៗ បានរស់នៅជាមួយគ្រួសាររបស់ពួកគាត់[124] និងទទួលបន្ទុកលើការងារផ្នែកកសិកម្ម[125]។ អ្នកទោសធ្ងន់ៗ

---

[119] *សូមមើល ឧទាហរណ៍* សេចក្តីរាយការណ៍របស់គណៈតំបន់ ៥ ប្រចាំសប្តាហ៍ ធ្វើនៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧, ឯកសារ D1.3.10.1 ត្រង់ទំព័រ ១០-១១។

[120] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ឃាង ឃុន ធ្វើនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ D119/143 ត្រង់ទំព័រ ១៦។

[121] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ពុំ ខូ ធ្វើនៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ D219/23 ត្រង់ទំព័រ ២១។ កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ១៤។

[122] *សូមមើល* កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ១៤ ទំព័រ២៧ និងទំព័រ៣៣។

[123] *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ឡាយ ខាន់ ធ្វើនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/4 ត្រង់ទំព័រ ៤។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី យក់ នាម ធ្វើនៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥, ឯកសារ D219/140 ត្រង់ទំព័រ ៥។

[124] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ព័រ ១៤។ *សូមមើលផងដែរ* កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ២៧។

បានធ្វើការងារនៅការដ្ឋានវាយថ្មមួយកន្លែង[126]ជាការលត់ដំ[127]ដើម្បីឲ្យពួកគាត់អាចត្រូវបានចាត់ថ្នាក់ជាថ្មីថាជាអ្នកទោសស្រាលបាន[128] ហើយនៅទីបំផុត ពួកគេនឹងត្រូវបានដោះលែង[129]។ ដូច្នេះ ភស្តុតាងបានបង្ហាញឲ្យឃើញថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ មិនត្រូវបានប្រព្រឹត្តឡើងក្នុងលក្ខណៈធ្ងន់ធ្ងរឡើយ បើប្រៀបធៀបទៅនឹងឧក្រិដ្ឋកម្មដទៃទៀតរបស់ខ្មែរក្រហម។ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅឯភ្នំទ្រយ៉ោង មិនអាចយកទៅពិពណ៌នាបានថាជាឧក្រិដ្ឋកម្ម "ធ្ងន់ធ្ងរបំផុត" ក្នុងបរិបទនៃអំពើឃោរឃៅទាំងស្រុងរបស់ខ្មែរក្រហមបានឡើយ។ បើទោះបីជាក្រុមការពារក្តីទទួលស្គាល់អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក៏ដោយ ក៏ភ្នំទ្រយ៉ោងមិនដូចគ្នាឡើយ បើធៀបនឹងមន្ទីរស២១ ដែលមន្ទីរនេះ បង្កើតឡើងសម្រាប់សួរចម្លើយ និង សម្លាប់រាល់អ្នកទាំងឡាយដែលទទួលរងនូវការចោទប្រកាន់ថាជាខ្មាំងនៃរបបកម្ពុជាប្រជាធិបតេយ្យ[130]។ ភ្នំទ្រយ៉ោងគ្រាន់តែជាមន្ទីរលត់ដំមួយក្នុងទម្រង់ជាសហករណ៍ប៉ុណ្ណោះ។

## កម្រិតនៃការទទួលខុសត្រូវ

៤៧. កម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទ ត្រូវបានវាយតម្លៃដោយផ្អែកទៅលើកម្រិតនៃការចូលរួមរបស់គាត់នៅក្នុងអំពើឧក្រិដ្ឋកម្ម ដែលមានឋានៈស្របតាមឋានានុក្រម ឬ តួនាទី និងភាព

---

[125] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D119/30 ត្រង់ទំព័រ ៦។ កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ៨ និង ១០។

[126] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ទុំ សឿន ធ្វើនៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/102 ត្រង់ទំព័រ ៩។

[127] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ទុំ សឿន ធ្វើនៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/102 ត្រង់ទំព័រ ៩។

[128] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ១៣។

[129] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ១៤ និងទំព័រ ២៧។

[130] *សូមមើល* សាលដីកា*ឌុច* ត្រង់កថាខណ្ឌ ២។

អចិន្ត្រៃយ៍នៃតួនាទីនោះ[131]។ ក្នុងការវាយតម្លៃអំពីកម្រិតនៃការទទួលខុសត្រូវរបស់ អ្នកស្រី អ៊ឹម ចែម នៅភ្នំទ្រយោង សហចៅក្រមស៊ើបអង្កេតត្រូវតែពិចារណាអំពីសិទ្ធិអំណាច *ជាក់ស្តែង* និងសិទ្ធិអំណាច*ស្របច្បាប់*របស់អ្នកស្រី[132]។ ចំណុចនេះ ត្រូវបានបញ្ជាក់បង្ហាញនៅក្នុងសំណុំរឿង០០១។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ឌុច "អាចត្រូវបានចាត់ទុកថាចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម...ដោយផ្អែកលើអំណាចឋានានុក្រមជាផ្លូវការ និងប្រកបដោយប្រសិទ្ធិភាពរបស់ខ្លួនក្នុងឋានៈជាអនុលេខា បន្ទាប់មកជាលេខា ក៏ដូចជាតាមរយៈការចូលរួមរបស់គាត់ដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរស២១ដែលជាមន្ទីរសន្តិសុខគ្រប់គ្រងផ្ទាល់ដោយគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា"[133]។

៤៨. មូលដ្ឋានតែមួយគត់នៃអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា "*ល្អប* ឃុំ និងកម្មាភិបាលភូមិភាគនិរតីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ [អ្នកស្រី] អ៊ឹម ចែម ជាអ្នកទទួលខុសត្រូវចំពោះការចាប់ខ្លួនប្រជាជន និងនាំយកប្រជាជនទៅសម្លាប់នៅភ្នំទ្រយោង"[134] គឺបានមកពីកិច្ចសម្ភាសន៍ប្រវែងមួយទំព័ររបស់ឈ្មោះ យ៉ែម កោង ដែលក្រោយមក សាក្សីរូបនេះ បានកែប្រែចម្លើយរបស់គាត់ទាំងស្រុង[135]។

៤៩. ភស្តុតាងតែមួយគត់ដែលបង្ហាញថាអ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចនៅភ្នំទ្រយោង គឺបានមកពីសាក្សី ទុំ សឿន ដែលតាមដឹងមកថា គាត់ជាប្រធាន[គុក]ភ្នំទ្រយោង ហើយសាក្សីរូបនេះ

---

[131] សាលក្រម*ឌុច* ត្រង់កថាខណ្ឌ ២២។

[132] *សូមមើលសំណុំរឿងរបស់លោក មាស មុត* សំណុំរឿងលេខ ០០៣/០៧ កញ្ញា ២០០៩/អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើយុត្តាធិការបុគ្គល និងគោលការណ៍ស៊ើបសួរទាក់ទងជនសង្ស័យ [កោសលប់] ធ្វើនៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២, ឯកសារ D49 ត្រង់កថាខណ្ឌ ២១។

[133] ដីកាដំណោះស្រាយនៃសំណុំរឿង ០០១ ត្រង់កថាខណ្ឌ ១២៩។

[134] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រង់កថាខណ្ឌ ៧៥, *យោង* កិច្ចសម្ភាសន៍របស់ SOAS/HRW ជាមួយ យ៉ែម កោង ធ្វើនៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥, ឯកសារ D1.3.11.66។

[135] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី យ៉ែម កៅ ធ្វើនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១១, ឯកសារ D45។ ក្រុមការពារក្តីកត់សម្គាល់ឃើញថា សាក្សី យ៉ែម កៅ និងសាក្សី យ៉ែម កោង តាមការពិតជាមនុស្សតែម្នាក់។

បាននិយាយថា គាត់បានទទួលការណែនាំពីអ្នកស្រី អ៊ឹម ចែម[136]។ ចម្លើយរបស់គាត់មិនអាចបញ្ជាក់បានថាជាការពិតឡើយនៅពេលផ្ទៀងផ្ទាត់តាមរយៈភស្តុតាងដទៃទៀត ដែលវាជាប្រការគួរឲ្យកត់សម្គាល់ ដោយសារមិនមានភស្តុតាងបង្ហាញពីអត្ថិភាពនៃរបាយការណ៍ជាលាយលក្ខណ៍អក្សររវាងអ្នកទាំងពីរ ហើយនីរសាររបស់អ្នកស្រី អ៊ឹម ចែម ទៀតសោត ក៏ពុំធ្លាប់ត្រូវបានគេធ្វើបទសម្ភាសន៍ម្តងណាឡើយ។ ក្រៅពីចម្លើយរបស់សាក្សី ទុំ សឿន ដែលជាចម្លើយមិនអាចបញ្ជាក់បានថាជាការពិត គឺគ្មានភស្តុតាងដទៃទៀតណាឡើយដែលបញ្ជាក់ថា អ្នកស្រី អ៊ឹម ចែម ពិតជាមានសិទ្ធិអំណាចណាមួយទៅលើនរណាម្នាក់ឡើយនៅភ្នំទ្រយោង បូករួមទាំងអ្នកយាមផងដែរ[137]។

៥០. លើសពីនេះ សាក្សី ទុំ សឿន មានចេតនាល្អបំផុត (ឬអាក្រក់បំផុត) ចំពោះការប៉ុនប៉ងទម្លាក់ការទទួលខុសត្រូវមកលើអ្នកស្រី អ៊ឹម ចែម ហើយភស្តុតាងរបស់គាត់ចាំបាច់ត្រូវឲ្យគេមើលឃើញក្នុងន័យនោះដែរ។ សាក្សីផ្សេងទៀត បានហៅ ទុំ សឿន ដូចៗគ្នាថាជាប្រធាននៅភ្នំទ្រយោង[138]

---

[136] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ទុំ សឿន ធ្វើនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/5, ទំព័រ ៥-៦។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ទុំ សឿន ធ្វើនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D119/65 ត្រង់ទំព័រ ២៩។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ទុំ សឿន ធ្វើនៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/102 ត្រង់ទំព័រ ៥-៦។ កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ១៤-១៥,២៨-២៩, ៣៥ និងទំព័រ ៣៧។

[137]ជាក់ស្តែង សាក្សី ស៊ុម សល់ ដែលជាអតីតឆ្មាំគុកម្នាក់នៅភ្នំទ្រយោង បាននិយាយថា គាត់មិនដែលឃើញអ្នកស្រី អ៊ឹម ចែម នៅទីនោះទេ។ គាត់និយាយទៀតថា ទុំ សឿន ជា "ប្រធានធំ" នៅភ្នំទ្រយោង។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ស៊ុម សល់ ធ្វើនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/7 ត្រង់ទំព័រ ៣-៤ និងទំព័រ ៦។

[138] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ គិម យ៉េត ធ្វើនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/6 ត្រង់ទំព័រ ៥។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ស៊ុម សល់ ធ្វើនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/7 ត្រង់ទំព័រ ៣-៤។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ធិប សំផាត់ ធ្វើនៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/8 ទំព័រ ៤។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ផុន ម៉ុន ធ្វើនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D119/19 ត្រង់ទំព័រ ៨។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ

និងបាននិយាយថា ពួកគាត់បានទទួលការណែនាំពី ទុំ សឿន និងបានរាយការណ៍ទៅកាន់បុគ្គលនេះដែរ[139]។ ទុំ សឿន ខ្លួនឯងផ្ទាល់ ទទួលស្គាល់ថា គាត់មានសិទ្ធិស្វយ័តខ្ពស់នៅភ្នំទ្រយោងមានន័យថា គាត់ជាអ្នកវាយតម្លៃថាតើអ្នកទោសណានឹងត្រូវចាត់ទុកជាអ្នកទោសធ្ងន់ ឬ អ្នកទោសស្រាល[140] គាត់មានសិទ្ធិអំណាចតែងតាំងអ្នកយាម[141] និងជាអ្នកសម្រេចថាតើអ្នកទោសណាខ្លះគួរត្រូវដោះលែង[142] ហើយថែមទាំងជាអ្នកសម្រេចថាតើគួរត្រូវសម្លាប់អ្នកទោសដែរឬទេ[143]។ សាក្សីក៏បានបញ្ជាក់អះអាងផងដែរថា ទុំ សឿន បានរស់នៅក្បែរជើងភ្នំត្រយោង ដែលមានចម្ងាយ

---

D119/30 ត្រង់ទំព័រ ៦។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការ ស្ដាប់ចម្លើយរបស់ ជុំ ជិម ធ្វើនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥, ឯកសារ D219/149 ត្រង់ទំព័រ ១១។

[139] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់ គិម យ៉េត ធ្វើនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/6 ត្រង់ទំព័រ ៧។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់ ស៊ុម សល់ ធ្វើនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២, D106/7 ត្រង់ទំព័រ ៣។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់ ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D119/30 ត្រង់ទំព័រ ៦-៧។

[140] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ១៣ ("ខ្ញុំទទួលមនុស្សយកទៅដាក់នៅកន្លែងខ្ញុំ ហើយវាយតម្លៃថាតើអ្នកទោសនោះចូលកម្រិតណា...ខ្ញុំវាយតម្លៃថាតើអ្នកនោះក្បត់មែន ឬមិនមែន") ត្រង់ទំព័រ ២៩ ("ពេលខ្លះ ខ្ញុំជាអ្នកសម្រេចប្ដូរចំណាត់ថ្នាក់ដោយខ្លួនខ្ញុំ")។

[141] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ១០ ("អ្នកខ្លះគឺជាអ្នកទោសស្រាលដែលខ្ញុំបានជ្រើសរើសឲ្យធ្វើជាអ្នកយាម")។ *សូមមើលផងដែរ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់ ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D119/30 ត្រង់ទំព័រ ៦ ("នៅពេលខ្ញុំបានប្រាប់ [ទុំ សឿន] ថាខ្ញុំឈ្មោះ ភួន ទី ជាអ្នកមកពីប្រាសាទ ពេលនោះគាត់បាននិយាយប្រាប់ខ្ញុំថាមិត្តឯងត្រូវធ្វើជាប្រធានអ្នកទោសទាំងអស់")។

[142] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារD230 ត្រង់ទំព័រ ២៧ ("ខ្ញុំធ្លាប់បានប្រជុំម្ដងនាពេលដែលវៀតណាមចូលមក ហើយបានប្រាប់ពួកគេ [អ្នកទោសនៅភ្នំទ្រយោង] ថា មកពីណាឲ្យត្រឡប់ទៅកន្លែងនោះវិញទៅ ពីព្រោះខ្ញុំមិនអាចការពារពួកគាត់ទៀតទេ") ត្រង់ទំព័រ២៨ ("ចំណុចខ្លះ ខ្ញុំបានធ្វើលើសតាមអារម្មណ៍ខ្លួនឯង...ខ្ញុំមើលឃើញមិនមានភាពធ្ងន់ធ្ងរ ខ្ញុំក៏ដោះលែង [អ្នកទោស] តាមការពិនិត្យរបស់ខ្ញុំ")។

[143] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ត្រង់ទំព័រ ៣៦ ("វាមិនអាចទៅរួចទេការសម្លាប់អ្នកណាមួយ ត្រូវមានការជូនដំណឹងពីខ្ញុំ")។ *សូមមើលផងដែរ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់ ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D119/30 ត្រង់ទំព័រ ៦ (ទុំ សឿន "បើបាត់តែម្នាក់គេនឹងវៃមិត្តឯងចោល")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់ ធិប សំផាត់ ធ្វើនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ D119/49 ត្រង់ទំព័រ ១១ ("តា សឿនជាអ្នកបញ្ជាឱ្យសម្លាប់")។

តែប៉ុន្មានម៉ែត្រប៉ុណ្ណោះពីកន្លែងដែលអ្នកទោសធ្ងន់ត្រូវបានសម្លាប់ នេះបើតាមការចោទប្រកាន់[144]។

៥១. បើទោះបីជាអ្នកស្រី អ៊ឹម ចែម ក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ មាន អំណាច*ស្របច្បាប់* ទៅលើ ទុំ សឿន ដោយសារថា ភ្នំទ្រយោងស្ថិតនៅក្នុងស្រុករបស់អ្នកស្រីកាន់កាប់ក៏ដោយ ក៏វាគ្មានតម្លៃជាភស្តុតាងណា បង្ហាញឱ្យឃើញថា អ្នកស្រីមានអំណាច*ជាក់ស្តែង* ដែលបានតម្រូវឱ្យអ្នកស្រីគ្រប់គ្រងមន្ទីរសន្តិសុខដូចត្រូវបានចោទប្រកាន់ ឬក៏ថាអ្នកស្រីជាប់ពាក់ព័ន្ធតាមបែបណាមួយនឹងគោលការណ៍របស់មន្ទីរសន្តិសុខនេះឡើយ។ រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធសន្តិសុខត្រូវបានបំបែកដាច់ដោយឡែកពីគ្នា[145]។ ភស្តុតាងជាក់ស្តែងបង្ហាញថា ភ្នំទ្រយោងត្រូវបានគ្រប់គ្រងដោយ ទុំ សឿន និងក៏បានបង្ហាញថា អ្នកស្រី អ៊ឹម ចែម ជាបុគ្គលពាក់ព័ន្ធក្នុងការកែប្រែមន្ទីរសន្តិសុខនេះឱ្យក្លាយទៅជាភូមិមួយ[146]។ តួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅភ្នំទ្រយោង ប្រសិនបើមាន គឺត្រឹមតែជាតួនាទីផ្តល់យោបល់ប៉ុណ្ណោះ[147]។ ចំណុចនេះ គឺស៊ីសង្វាក់ជាមួយនឹងចម្លើយរបស់សាក្សីមួយចំនួន ដែលបាននិយាយថាពួកគាត់ពុំដែលបានឃើញអ្នកស្រី អ៊ឹម ចែម នៅភ្នំ

[144] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ផុន ម៉ុន ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/95 ទំព័រ ៤។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/92 ទំព័រ ១១។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ គិម យ៉េត ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/94 ទំព័រ ១២។

[145] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ជុំ កាន់ ធ្វើនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D119/110 ទំព័រ ៨។

[146] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ទុំ សឿន ធ្វើនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/5 ទំព័រ ៥។

[147] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ទំព័រ ១៤ ("ខ្ញុំធ្លាប់ជជែកពិភាក្សាតទល់មុខគ្នា [ជាមួយអ្នកស្រី អ៊ឹម ចែម] នៅពេលយើងចង់ដោះលែងអ្នកទោសស្រាល...យើងទាំងអស់គ្នាឯកភាពដោះលែង") ទំព័រ ១៥ (អ្នកស្រី អ៊ឹម ចែម "ណែនាំពីការដោះស្រាយជីវភាព គ្រប់គ្រងកម្លាំង ការណែនាំកុំឱ្យពួកខ្ញុំហូបចុកលើសពីប្រជាជន ក៏ដូចជាកុំឱ្យផ្តល់របបហូបលើសពីកន្លែងផ្សេង"។

ទ្រយោងទេ[148] ។ ចំពោះអ្នកស្រី អ៊ឹម ចែម ផ្ទាល់ នៅក្នុងកិច្ចសម្ភាសន៍បរិយាយជាច្រើនដែលអ្នកស្រីបានផ្តល់ គ្មានម្តងណាឡើយ ដែលអ្នកស្រីបានទទួលស្គាល់ថា ខ្លួនមានតួនាទីណាមួយនៅទីតាំងឧក្រិដ្ឋកម្មនោះ[149]។

៥២. ភស្តុតាងនេះមិនបានបង្ហាញថាអ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចហួសពីអ្វីដែលលេខាស្រុកធម្មតាម្នាក់មាននោះឡើយ។ អ្នកស្រីត្រូវបានតែងតែងជាលេខាស្រុកព្រះនេត្រព្រះពីពាក់កណ្តាលឆ្នាំ ១៩៧៧ និងបានរក្សាទុកតួនាទីនេះរហូតដល់របបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់។ ភស្តុតាងដែលបានដាក់ក្នុងសំណុំរឿង បានបង្ហាញថាក្នុងតួនាទីរបស់អ្នកស្រីជាលេខាស្រុក ត្រូវបានកំហិតឲ្យត្រួតពិនិត្យតាមភូមិ និងឃុំនានា នៅក្នុងស្រុកព្រះនេត្រព្រះ[150]។ សាក្សីនានារំលឹកឡើងវិញថាអ្នកស្រី អ៊ឹម ចែម បានត្រឹមតែធ្វើកិច្ចពិភាក្សាអំពីការផលិតស្បៀងប៉ុណ្ណោះក្នុងពេលមានប្រជុំ

---

[148] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ស៊ុម សល់ ធ្វើនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/7 ទំព័រ ៦។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ផុន ម៉ុន, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D119/19 ទំព័រ ១០។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D119/30 ទំព័រ ៧។

[149] *សូមមើល* ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧, ឯកសារ D1.3.28.4។ កិច្ចសម្ភាសន៍ របស់ផលិតកម្ម Smiling Toad ជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, ឯកសារ D1.3.12.1។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ដែលត្រូវបានថតសំឡេងជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, ឯកសារ D6.1.75។ ប្រតិចារឹកកិច្ចសម្ភាសន៍ជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨, ឯកសារ D123/1/5.1b។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយញអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D123/1/5.1c។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់អង្គការយុវសន្តិភាព ជាមួយ អ៊ឹម ចែម ក្នុងឆ្នាំ ២០១១, គ្មានកាលបរិច្ឆេទ, ឯកសារ D219/264.1។ ក្រុមការពារក្តីកត់សម្គាល់ឃើញថា ក្នុងកិច្ចសម្ភាសន៍មួយ អ្នកស្រី អ៊ឹម ចែម បាននិយាយថា អ្នកស្រីបានដឹងឮពីភ្នំទ្រយោង ប៉ុន្តែអ្នកស្រីបាននិយាយថាភ្នំទ្រយោងប្រហែលជាស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ខេត្ត និងថា អ្នកស្រីមិនបានគ្រប់គ្រងវាឡើយ។*សូមមើល*ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D123/1/5.1c ទំព័រ ៣៤-៣៥។

[150] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ឈឹម ផន ធ្វើនៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣, ឯកសារ D119/32 ទំព័រ ៧។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី យ៉េង ឆាន ធ្វើនៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤, ឯកសារ D119/132 ទំព័រ ៦។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ពុំ ខូ ធ្វើនៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ D219/23 ទំព័រ ៦។

ម្តងៗ[151]។ សាក្សី ទុំ សឿន ក៏ទទួលស្គាល់ថាការណែនាំរបស់អ្នកស្រី អ៊ឹម ចែម ជានិច្ចកាល គឺអំពីប្រធានបទនេះដែរ[152]។ ការបង្ហាញផ្សេងៗតែមួយគត់ពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម នៅភ្នំទ្រយោង គឺផ្អែកលើការស្មានសុទ្ធសាធ ឬ ការមានទំនាក់ទំនងជាមួយការិយាល័យរបស់អ្នកស្រី[153] ដែលទាំងអស់នេះ សុទ្ធតែមិនអាចជឿជាក់បាននោះទេ។ ចំណុចនេះ ត្រូវបានបង្ហាញដោយសាក្សី ស៊ុម សល់ ដែលបានរំលឹកអំពីការប្រជុំមួយរៀបចំឡើងដោយអ្នកស្រី អ៊ឹម ចែម នៅភ្នំលៀប ដែលអ្នកចូលរួមមានតែឆ្មាំគុកមកពីភ្នំទ្រយោងប៉ុណ្ណោះ ឬក៏រួមទាំងគាត់ផងដែរ។ សាក្សី ស៊ុម សល់ បាននិយាយថា ក្នុងពេលប្រជុំ អ្នកស្រី អ៊ឹម ចែម មិនបានលើកឡើងឡើយអំពីស្ថានភាពអ្វីទាំងអស់នៅភ្នំទ្រយោង ប៉ុន្តែអ្នកស្រី អ៊ឹម ចែម បានលើកអំពីការមកដល់របស់កងទ័ពវៀតណាមទៅវិញ[154]។ ប្រសិនបើអ្នកស្រី អ៊ឹម ចែម ជាអ្នកមានតួនាទីដែលមានសិទ្ធិអំណាចនៅភ្នំទ្រយោងមែននោះ វាមិនសមហេតុផលទេ ដែលអ្នកស្រីមិននិយាយពីភ្នំទ្រយោងទាល់តែសោះនៅក្នុងអង្គប្រជុំ ដែលមានអ្នកចូលរួមសុទ្ធតែឆ្មាំគុកភ្នំទ្រយោង ឬ បើមិនដូច្នោះទេ អ្នកស្រីមិនបានបង្ហាញនូវសិទ្ធិអំណាចរបស់អ្នកស្រីតាមរយៈការប្រជុំនោះឡើយ។

---

[151] *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D119/30 ទំព័រ ៤។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ឈឹម ផន ធ្វើនៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣, ឯកសារ D119/32 ទំព័រ ៧។

[152] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ទុំ សឿន ធ្វើនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D106/5 ទំព័រ ៦។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ទុំ សឿន ធ្វើនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D119/65 ទំព័រ ១៤។ កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D230 ទំព័រ ១៤-១៥។

[153] *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី មុន មុត ធ្វើនៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤, ឯកសារ D119/139 ទំព័រ ១៣ (ភាសាខ្មែរ) ("តាមរយៈបទពិសោធន៍របស់ខ្ញុំក្នុងសម័យនោះ ក្នុងនាមគាត់ជាគណៈស្រុកព្រះនេត្រព្រះ ដូច្នេះគាត់អាចមានតួនាទី និងសិទ្ធិអំណាចគ្រប់គ្រងនៅក្នុងគុកទាំងពីរនោះហើយ ពីព្រោះគុកទាំងពីរនោះវាស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ")។

[154] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ស៊ុម សល់ ធ្វើនៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/103 ទំព័រ ១១-១២។

៥៣. ភស្តុតាងតែមួយគត់ដែលភ្ជាប់អ្នកស្រី អ៊ឹម ចែម ទៅនឹងការបញ្ជាឲ្យចាប់ខ្លួន គឺជាលិខិតមួយច្បាប់ ដែលតាមដឹង ថា ទុំ សឿន បានបង្ហាញទៅ ធិប សំផាត់ នៅពេល ទុំ សឿន មកដល់ភ្នំទ្រយោង[155]។ សាក្សី គិម យ៉េត ដែល ធិប សំផាត់ និយាយថា ក៏មានឈ្មោះក្នុងសំបុត្រនោះដែរ បានបដិសេធចម្លើយពីមុនរបស់ខ្លួន ត្រង់ចំណុចដែលគាត់បាននិយាយថាអ្នកស្រី អ៊ឹម ចែម បាន បញ្ជាឲ្យគេចាប់ខ្លួនគាត់[156]។ ដោយពុំមានការទទួលស្គាល់ណាមួយនូវភាពគួរឲ្យជឿជាក់បាននៃ ការបង្ហាញរបស់ ធិប សំផាត់[157] ហើយនេះជាករណីតែមួយគត់ដែលអ្នកស្រី អ៊ឹម ចែម បាន បញ្ជូនអ្នកទោសម្នាក់ទៅភ្នំទ្រយោង។ គ្មានភស្តុតាងណាដែលថាលិខិតនេះ ពិតជាការបញ្ជា ឲ្យចាប់ខ្លួន ឬជាការអញ្ជើញឲ្យទៅចូលរួមប្រជុំ ដូចករណីរបស់ ភួន ស៊ុនទី និង ផុន ម៉ុន ជាដើម[158]។ ទោះជាក្នុងករណីណាក៏ដោយ អំណះអំណាងរបស់សាក្សី ធិប សំផាត់ មិនត្រូវបានគាំទ្រដោយភស្តុតាងរូបវន្តណាមួយទេ ដូច្នេះ អំណះអំណាងនេះ គួរមានតម្លៃអាច ឲ្យជឿជាក់បានតិចតួចបំផុត។

៥៤. ជាចុងក្រោយ មានតែភស្តុតាងចេញពីសាក្សី ទុំ សឿន ទេ ដែលបានភ្ជាប់អ្នកស្រី អ៊ឹម ចែម ទៅនឹង

---

[155] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ធិប សំផាត់ ធ្វើនៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D106/8 ទំព័រ ៣។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ធិប សំផាត់ ធ្វើនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ D119/49 ទំព័រ ៩។

[156] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ គិម យ៉េត ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/94 ទំព័រ ៤-៥។

[157] មេធាវីការពារក្តីកត់សម្គាល់ឃើញថាសាក្សី ធិប សំផាត់ បានជូនដំណឹងទៅអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ថាគាត់ "មានបញ្ហាផ្លូវចិត្តពីព្រោះនៅពេលមួយនោះ ឈើមួយកំណាត់បានធ្លាក់ត្រូវក្បាលរបស់គាត់...[និង] ថាឧប្បត្តិហេតុនេះបានកើតឡើងមុនពេលគាត់បានផ្តល់កិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងខែ កញ្ញា ឆ្នាំ ២០១១" *ទោះគឺ* មុនពេលគាត់បាន អះអាងពីដំបូងថាអ្នកស្រី អ៊ឹម ចែម បានចេញលិខិតបញ្ជាឲ្យគេចាប់គាត់។ *សូមមើល*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃ ការស្តាប់ចម្លើយរបស់ ធិប សំផាត់ ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/93 ទំព័រ ៣-៤។

[158] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ភួន ស៊ុនទី ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/92 ទំព័រ ៦។ *សូមមើលផងដែរ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ផុន ម៉ុន ធ្វើនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ D219/95 ទំព័រ ៤ និងទំព័រ ៧ (យោងនូវលិខិតដែល ភួន ស៊ុនទី បានទទួលក្នុងឆ្នាំ ១៩៧៨ និងបដិសេធថាវាពុំមែនជាបញ្ជាឲ្យចាប់រូបគាត់ឡើយ)។

ការសម្លាប់នៅភ្នំទ្រយោង ហើយវាជាភស្តុតាងនេះមិនបានបញ្ជាក់ថាជាការពិតនៅឡើយ ។ សាក្សី ទុំ សឿន បានបញ្ជាក់ថា នៅពេលវៀតណាមបានចូលមកដល់ អ្នកស្រី អ៊ឹម ចែម បានណែនាំគាត់ឱ្យសម្លាប់អ្នកទោសប្អូននាក់ដែលពុំអាចដើរកើត ឬអាចរត់យករួចខ្លួនពីកងទ័ពវៀតណាមបាន[159]។ ភស្តុតាងនេះ មិនស៊ីសង្វាក់ជាមួយភស្តុតាងពីការស្តាប់ចម្លើយមុនៗរបស់សាក្សីរូបនេះឡើយ[160] ហើយវាបានមកនៅក្រោយពេលដែលមានការដាក់សម្ពាធក្នុងអំឡុងរយៈពេលប៉ុន្មានឆ្នាំពីសំណាក់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ដើម្បីធ្វើឱ្យមានការជាប់ពាក់ព័ន្ធនឹងអ្នកស្រី អ៊ឹម ចែម ប៉ុណ្ណោះ។ ជាការពិត ទុំ សឿន មានចេតនាកុហក ដើម្បីវាសវាងពីការជាប់ពាក់ព័ន្ធរបស់ខ្លួនទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នេះ[161] ហើយបំណងរបស់គាត់ក្នុងកាលទេសៈនៈ គឺដើម្បីគេចចេញពីការទទួលខុសត្រូវរបស់ខ្លួន។ មិនត្រឹមតែភស្តុតាង*បឋម* មិនអាចជឿជាក់បាននោះទេ ប៉ុន្តែការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងការសម្លាប់ទាំងនេះ មិនសមស្របសម្រាប់យកទៅពិចារណាដោយសហចៅក្រមស៊ើបអង្កេតឡើយ ព្រោះតែវាខ្វះភាពគួរឱ្យជឿជាក់បាន។ ប្រការនេះ បង្ហាញឱ្យឃើញថាគ្មានភស្តុតាងផ្ទាល់ណាមួយ សម្រាប់ទាញភ្ជាប់អ្នកស្រី អ៊ឹម ចែម ឱ្យជាប់ពាក់ព័ន្ធទៅនឹងការសម្លាប់នានាដែលត្រូវបានចោទប្រកាន់នោះឡើយ។ បើទោះបីជា ចម្លើយរបស់សាក្សី ទុំ សឿន បានបង្ខូចតម្លៃភស្តុតាងទាក់ទងនឹងការចេញបញ្ជារបស់អ្នកស្រី អ៊ឹម ចែម ឱ្យសម្លាប់អ្នកទោសប្អូនរូបត្រូវបានទទួលស្គាល់តាមសម្បកក្រៅក៏ដោយ ក៏ភស្តុតាងនោះ អាចបញ្ជាក់បានត្រឹមការទទួលខុសត្រូវរបស់អ្នកស្រីចំពោះការសម្លាប់មនុស្សចំនួន៤នាក់នោះតែប៉ុណ្ណោះ។ ទោះបីជារាល់ការចោទប្រកាន់អំពីការសម្លាប់ គឺជានិច្ចកាលជារឿងធ្ងន់ធ្ងរមួយក៏ដោយ អ្នកស្រី អ៊ឹម ចែម នៅតែមិនត្រូវអាចចាត់ទុកថាមានតួនាទី (តួនាទីជាឧបករណ៍) សំខាន់អ្វីឡើយនៅភ្នំទ្រយោង។

---

[159] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤,ឯកសារ D230 ទំព័រ ២៩។

[160] *សូមមើល* ប្រតិចារឹកនៃការស្តាប់ចម្លើយរបស់សាក្សី ទុំ សឿន ធ្វើនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D219/422.9 ទំព័រ ៣០។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី ទុំ សឿន ធ្វើនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D119/65 ទំព័រ ៣៧ និងទំព័រ ៤០។

[161] កំណត់ហេតុនៃការតទល់មុខគ្នា ធ្វើនៅថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ២០១៤,ឯកសារ D230 ទំព័រ ២៩។

## ខ.៤ សេចក្តីសន្និដ្ឋានស្តីពីការដ្ឋានស្ពានស្រែង និងមន្ទីរសន្តិសុខភ្នំទ្រយោង

៥៥. ដូចដែលបានអះអាងខាងលើ[162] ឌុច បានក្លាយជាគោលដៅសម្រាប់យោងនៅពេលត្រូវពន្យល់ថា មន្ត្រីខ្មែរក្រហមណាខ្លះស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ ឌុច ជាអតីតអនុប្រធានមន្ទីរស២១ ដែលជាមន្ទីរឃុំឃាំង ព្រមទាំងជាកន្លែងសម្លាប់មនុស្ស និងជាជំរំលត់ដំ ចាប់ពីខែតុលា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ។ មន្ទីរនេះ បានធ្វើឲ្យជនរងគ្រោះស្លាប់ចំនួន ១២.២៧២ នាក់ ដែលភាគច្រើននៃជនរងគ្រោះសុទ្ធតែត្រូវបានរងទារុណកម្មជាប្រព័ន្ធ[163]។ មន្ទីរស២១ គឺជាតឹកតាងរបស់ជាតិ និងអន្តរជាតិសម្រាប់បង្ហាញពីនិមិត្តរូបនៃអំពើឃោរឃៅរបស់ខ្មែរក្រហម និងអំពើអមនុស្សធម៌របស់មនុស្សធ្វើចំពោះមនុស្ស ហេតុនេះហើយ ជារឿងធម្មតានៅក្នុងយុត្តិធម៌អន្តរជាតិដែលតម្រូវឲ្យមានការផ្តន្ទាទោសប្រធានមន្ទីរស២១ ទោះបីជាការពិតគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់ក៏ដោយ។ ការពិតគឺថា ឌុច បានស្ថិតក្នុងចំណោម "កម្មាភិបាលថ្នាក់ទាបដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរបំផុត"[164] និងស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្រោមវិសាលភាពនៃកិច្ចព្រមព្រៀង។

៥៦. ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានទទួលរងការចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់អ្នកស្រីដែលត្រូវបានចោទប្រកាន់នៅការដ្ឋានស្ពានស្រែង និងមន្ទីរសន្តិសុខភ្នំទ្រយោងមិនស្រដៀងគ្នាសូម្បីតែបន្តិចទៅនឹងកាលៈទេសៈរបស់ ឌុច ដែលជាបុគ្គលគោលដៅម្នាក់សម្រាប់យោងក្នុងការកំណត់ថាតើបុគ្គលណាខ្លះស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅមន្ទីរស២១។ វាមិនអាចទៅរួចនោះទេ ចំពោះការប្រៀបធៀបដ៏សមហេតុផល និងប្រកបដោយវិចារណញ្ញាណរវាងករណីទាំងពីរនេះ ។

៥៧. ភស្តុតាងដែលមាន មិនអាចធ្វើឲ្យលេចចេញជារូបរាងបានដែលថាលេខាស្រុកម្នាក់ជាអ្នកបាន

---

[162] *សូមមើលឯកសារយោងខាងលើ* ត្រង់កថាខណ្ឌ ១៦-១៨។

[163] សាលដីកា *ឌុច* ត្រង់កថាខណ្ឌ ២-៣។

[164] របាយការណ៍របស់ក្រុមអ្នកជំនាញ ត្រង់កថាខណ្ឌ ១១០។

ប្រព្រឹត្ត បានរៀបចំផែនការ បានញុះញង់ បានបញ្ជា ឬ បានជួយជំរុញឲ្យមានអំពើឧក្រិដ្ឋកម្មដ៏ "ធ្ងន់ធ្ងរបំផុត" នៅការដ្ឋានស្ពានស្រែង និងមន្ទីរសន្តិសុខភ្នំទ្រយ៉ោង។ ភស្តុតាងមិនបានបង្ហាញថា អ្នកស្រី អ៊ឹម ចែម ពិតជាមានតួនាទីសំខាន់អ្វីនៅក្នុងទីតាំងឧក្រិដ្ឋកម្មទាំងពីរឡើយ។ ភស្តុតាងទាំងនេះ បែរជាបង្ហាញយ៉ាងស្របគ្នាថា អ្នកស្រី អ៊ឹម ចែម ក្នុងនាមជាលេខាស្រុកម្នាក់ គឺជាអ្នកដោះស្រាយលើការផលិតស្បៀង និងការរស់នៅរបស់ប្រជាជននៅស្រុកព្រះនេត្រព្រះ។ ហេតុដូច្នេះ អ្នកស្រី អ៊ឹម ចែម មិនអាចទាល់តែសោះនឹងត្រូវចាត់ចូលទៅក្នុងប្រភេទ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" លើឧក្រិដ្ឋកម្មនៅការដ្ឋានស្ពានស្រែង និងមន្ទីរសន្តិសុខភ្នំទ្រយ៉ោងឡើយ ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នឹងមិនអាចអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់គាត់បានសមហេតុផលនោះទេ ប្រសិនបើអ្នកស្រី អ៊ឹម ចែម ត្រូវបានស៊ើបអង្កេតដោយផ្អែកលើមូលដ្ឋានថា អ្នកស្រីនៅក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចយុត្តាធិការលើរឿងក្តីរបស់តុលាការ។

## គ. ការជ្រើសយក អ្នកស្រី អ៊ឹម ចែម មកចោទប្រកាន់ និងដាក់ឲ្យស្ថិតក្រោមការពិនិត្យ គឺផ្ទុយទៅនឹងគោលបំណងរបស់ភាគីនៅក្នុងកិច្ចព្រមព្រៀង

៥៨. ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "ក្នុងកម្រិតអប្បបរមានៃពាក្យថា "មេដឹកនាំជាន់ខ្ពស់ កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" បានឆ្លុះបញ្ចាំងនូវគោលបំណងរបស់អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រមូលផ្តុំធនធានមានកម្រិត ដើម្បីធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋទៅលើកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលកំពុងនៅរស់រានមានជីវិត"[165]។ ការលើកឡើងនេះ ស្របជាមួយក្រុមអ្នកជំនាញដែលបានជំទាស់ទៅនឹងការបង្កើតតុលាការមួយ ដែលបានកំណត់ឈ្មោះទុកជាមុននូវបុគ្គលដែលត្រូវចោទប្រកាន់[166] បានផ្តល់អនុសាសន៍ថា មិនមែនអតីតខ្មែរក្រហមទាំងអស់ដែលបានប្រព្រឹត្ត

[165] សាលដីកា *ឌុច* ត្រង់កថាខណ្ឌ ៥២។

[166] របាយការណ៍របស់ក្រុមអ្នកជំនាញ ត្រង់កថាខណ្ឌ ១១១។

អំពើរំលោភបំពានច្បាប់អន្តរជាតិ ឬ ច្បាប់កម្ពុជាចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គួរត្រូវបាន ជំនុំជម្រះឡើយ[167]។

៥៩. ការជ្រើសរើសយកតែអ្នកស្រី អ៊ឹម ចែម មកធ្វើការចោទប្រកាន់ និងស៊ើបអង្កេត នៅពេលភស្តុតាងដែលមានបានបង្ហាញថា អ្នកស្រីមិនស្ថិតក្នុងប្រភេទណាមួយក្នុងចំណោមបុគ្គលទាំងពីរប្រភេទនោះ ខណៈដែលមានបុគ្គលដទៃទៀតដែលកំពុងនៅរស់រានមានជីវិត បានដើរតួនាទីសំខាន់ជាងអ្នកស្រីក្នុងអំពើឧក្រិដ្ឋកម្មផ្សេងៗប្រព្រឹត្តទៅក្រោមរបបនេះ គឺពិតជាស្ថានភាពមួយដែលអង្គការសហប្រជាជាតិបានព្យាយាមបញ្ចៀស នៅពេលខ្លួនបានបង្កើត អ.វ.ត.ក ឡើង និងជាអ្វីដែលអង្គការសហប្រជាជាតិបានថ្កោលទោស[168]។ អ្នកស្រី អ៊ឹម ចែម បានក្លាយជាកម្មវត្ថុនៃយុត្តិធម៌រើសអើង អស់រយៈពេលចំនួនជាងប្រាំមួយឆ្នាំ ដោយគ្រាន់តែអ្នកស្រីមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីប៉ុណ្ណោះ។ ហេតុនេះ វាផ្ទុយស្រឡះពីគោលបំណងនៃកិច្ចព្រមព្រៀង បើនៅតែបន្តប្រតិបត្តិការនូវទម្រង់យុត្តិធម៌រើសអើងនេះ ។ ការស៊ើបអង្កេតទៅលើអ្នកស្រី អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មសម័យខ្មែរក្រហម នៅពេលដែលកិច្ចស៊ើបសួរមិនទាំងអាចផ្តួចផ្តើមបង្កើតឲ្យឃើញថា សូម្បីតែការថ្លឹងថ្លែងនៃភាពដែលអាចទៅរួច ដែលថាអ្នកស្រីជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចយុត្តាធិការរឿងក្តីរបស់តុលាការនេះ។

---

[167] របាយការណ៍របស់ក្រុមអ្នកជំនាញ ត្រង់កថាខណ្ឌ ១១០។

[168] *សូមមើល* ការពិនិត្យប្រវត្តិការចរចារបស់ Heder ទំព័រ ២៦ (ដែលរម្លឹកឡើងវិញអំពីកំណត់សម្គាល់របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលយោងតាមកំណត់សម្គាល់នោះ "ការជំនុំជម្រះមេដឹកនាំខ្មែរក្រហមដែលត្រូវបានជ្រើសរើស ដែលនឹងបន្សល់ទុកការមិនផ្តន្ទាទោសមេដឹកនាំសំខាន់ៗដទៃទៀត...នឹងមិនបម្រើបុព្វហេតុយុត្តិធម៌ និងការទទួលខុសត្រូវ")។

## IV. សេចក្តីសន្និដ្ឋាន

៦០. រាល់ភស្តុតាងដែលប្រមូលបានមកទល់ពេលបច្ចុប្បន្ននេះ បានបង្ហាញតាមដែលអាចធ្វើទៅបានពីការថ្លឹងថ្លែងនៃភាពដែលអាចទៅរួចចំពោះអ្នកស្រី អ៊ឹម ចែម គឺថាអ្នកស្រីមិនមែនជា "មេដឹកនាំជាន់ខ្ពស់" ហើយក៏មិនស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងឡើយ។ ដោយសារតែកិច្ចស៊ើបសួរបានប្រព្រឹត្តទៅអស់ចំនួនជាងប្រាំមួយឆ្នាំ និងកំពុងជិតបញ្ចប់ដូច្នេះ យើងមិនឃើញមានលទ្ធភាពប្រាកដប្រជាអ្វីដែលថានឹងមានភស្តុតាងថ្មីត្រូវបានរកឃើញ ដើម្បីអាចបដិសេធការសន្និដ្ឋាននេះគឺគ្មានឡើយ។ កិច្ចស៊ើបសួរពុំអាចប្រព្រឹត្តទៅជារៀងរហូតជាមួយនឹងក្តីសង្ឃឹមដ៏ស្តួចស្តើងដែលថា នឹងអាចរកឃើញនូវភស្តុតាងដាក់បន្ទុកដើម្បីបង្ហាញពីតួនាទីជាន់ខ្ពស់របស់អ្នកស្រី ឬក៏កម្រិតនៃការទទួលខុសត្រូវរបស់អ្នកស្រីដូច្នេះបានឡើយ។ បន្ទាប់ពីរយៈពេលប្រាំមួយឆ្នាំកន្លងផុត វាដល់ពេលដែលត្រូវសន្និដ្ឋានថា ភស្តុតាងទាំងនេះបង្ហាញយ៉ាងលើសលុបថាអ្នកស្រី អ៊ឹម ចែម ពុំស្ថិតក្នុងប្រភេទបុគ្គលណាមួយដែលភាគីនៃកិច្ចព្រមព្រៀងបានកំណត់សម្រាប់ការចោទប្រកាន់នោះទេ។

## V. សំណើសុំដោះស្រាយ

អាស្រ័យហេតុនេះ ដោយផ្អែកលើសេចក្តីសង្កេតដូចដែលបានលើកឡើងខាងលើ ក្រុមការពារក្តី សុំស្នើឲ្យសហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ និងដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ សហចៅក្រមស៊ើបអង្កេត (ក) សម្រេចថាអ្នកស្រី អ៊ឹម ចែម ពុំមែនជា "មេដឹកនាំជាន់ខ្ពស់" ឬ ក៏ជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការលើរឿងក្តីរបស់តុលាការនេះឡើយ និង (ខ) បដិសេធការចោទប្រកាន់ទាំងឡាយ មកលើអ្នកស្រី អ៊ឹម ចែម។

សូមមេត្តាទទួលយកសំណើនេះដោយគោរព៕

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥
សហមេធាវីការពារក្ដីរបស់អ្នកស្រី អ៊ឹម ចែម

| [ ] | [ ] |
| --- | --- |
| ប៉ិត ស៊ាងលឹម | John R.W.D. JONES QC |